ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០១៥/២១ - គួ តាយ ហ៊័រ សេង ស៊ីន ហ្វេង ជីង

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ុង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ស៊ីន គីមស៊ាន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន គួ តាយ ហ៊័រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន**

អាសយដ្ឋាន ៖ ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៩៦ ៦៩ ៦៥ ៥៨១ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក វិញ សួស ម៉ាន់ | ប្រធានរដ្ឋបាល |
| ២- លោកស្រី វិញ ស៊ុយ យ៉ាវ | គណនេយ្យ |
| ៣- លោក តោ ដារ៉ាវិទ្ធ | មន្ត្រីការងារសមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC) |

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **សហជីពប្រជាធិបតេយ្យកម្មករ នៃក្រុមហ៊ុន គួ តាយ ហ៊័រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន**

អាសយដ្ឋាន ៖ ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៩៨ ៣៥ ១៩ ៩២ / ០១២ ៥០ ៤១ ៥៤ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក ស៊ាង យ៉ូត | មន្ត្រីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ២- លោកស្រី អ៊ឹម សុភាព | ប្រធានសហជីពប្រជាធិបតេយ្យកម្មករ |
| ៣- លោក ខឿន វដ្ឋា | អនុប្រធានសហជីពប្រជាធិបតេយ្យកម្មករ |
| ៤- កញ្ញា ស៊ិន យាប | លេខាសហជីពប្រជាធិបតេយ្យកម្មករ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ស្នើនិយោជកផ្តល់ និងរក្សាអត្ថប្រយោជន៍ដែលបានបាត់បង់ ដូចជា ប្រាក់រង្វាន់តាមក្តាខៀន ប្រាក់រង្វាន់តាមម៉ាស៊ីន ប្រាក់រង្វាន់ដេរស៊ីបុង ប្រាក់រង្វាន់ដេរជ្រុងស្លាយ ដូចដើមវិញ។ ដោយឡែក ភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនគ្មានលទ្ធភាពផ្តល់ជូនតាមការស្នើសុំរបស់កម្មករនិយោជិតនោះទេ ដោយសាររយៈពេលកន្លងមកនេះ និយោជកខាតបង់ ព្រោះផលិតផលផលិតមិនទាន់កាលកំណត់របស់អ្នកបញ្ជាទិញផលិតផល បាត់បង់ទំនុកចិត្តបាត់បង់អ្នកបញ្ជាទិញ ដោយសារតែកម្មករមិនចូលធ្វើការ មិនចូលរួមសហការក្នុងអំឡុងពេលដែល មានការពន្លឿនផលិតផល បន្ទាប់ពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ១៩ វាជាហេតុនាំឱ្យក្រុមហ៊ុនខាតបង់ និងត្រូវតែអនុវត្តតាមគោលការណ៍ថ្មី។

២- ស្នើនិយោជកផ្តល់ប្រាក់ឈ្នួលសម្រាប់ខែមេសា ឆ្នាំ២០២១ ចាប់ពីថ្ងៃទី១ រហូតដល់ថ្ងៃទី១៤ ចំនួន ១០០%(មួយរយភាគរយ) និងចាប់ពីថ្ងៃទី១៥ រហូតដល់ថ្ងៃទី៣០ ចំនួន ៥០%(ហាសិបភាគរយ) ដល់កម្មករនិយោជិត។ ដោយឡែក ភាគីក្រុមហ៊ុនបញ្ជាក់ថា ចំពោះការផ្តល់ប្រាក់ឈ្នួលសម្រាប់ខែមេសា ឆ្នាំ២០២១ ចាប់ពីថ្ងៃទី១ រហូតដល់ថ្ងៃទី១៤ គឺក្រុមហ៊ុនបានបំពេញកាតព្វកិច្ចបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតរួចរាល់ហើយ ស្របតាមសេចក្តីណែនាំលេខ ០៤៣/២១ ក.ប/ស.ណ.ន.ខ.ល ស្តីពីការបើកប្រាក់ឈ្នួលដើមខែមេសា និងប្រាក់ឧបត្ថម្ភបន្ថែមរបស់រោងចក្រ សហគ្រាស សិប្បកម្ម និងក្រុមហ៊ុនដល់កម្មករនិយោជិតក្នុងអំឡុងពេលនៃការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ និងសេចក្តីជូនដំណឹងលេខ ០២២/២១ ក.ប/ស.ជ.ណ.ខ.ល ស្តីពីការចូលធ្វើការឡើងវិញ និងការបើកប្រាក់ឈ្នួលរបស់បងប្អូនកម្មករនិយោជិតនៅតាមរោងចក្រ សហគ្រាសដែលបើកឱ្យដំណើរការឡើងវិញ ក្រោយការបញ្ចប់វិធានការបិទខ្ទប់ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២១។ ដោយឡែក ចាប់ពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ ក្រុមហ៊ុនពុំមានលទ្ធភាពផ្តល់ជូនទៅតាមការស្នើសុំនោះឡើយ ដោយសារក្រុមហ៊ុនបានអនុវត្តទៅតាមសេចក្តីណែនាំ សេចក្តីជូនដំណឹង និងច្បាប់ស្តីការងាររួចហើយ។

៣- ស្នើនិយោជកបើកប្រាក់ឈ្នួលចំនួន ១០០%(មួយរយភាគរយ) សម្រាប់ខែឧសភា ឆ្នាំ២០២១ ជូនកម្មករនិយោជិតដែលស្ថិតក្នុងវិធានការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាលរបស់រាជរដ្ឋាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ១៩។ ដោយឡែក ភាគីនិយោជកបញ្ជាក់ថា ភាគីនិយោជកគ្មានលទ្ធភាពផ្តល់ជូនតាមការស្នើសុំរបស់កម្មករនិយោជិតនោះទេ ដោយសារនិយោជកបានអនុវត្តតាមច្បាប់។

៤- ស្នើនិយោជកផ្តល់លទ្ធភាពឱ្យកម្មករនិយោជិតធ្វើការទទួលប្រាក់ឈ្នួលប្រចាំថ្ងៃ បានចូលបម្រើការងារក្នុងរោងចក្ររៀងរាល់ថ្ងៃ និងទទួលបានប្រាក់រង្វាន់លើកទឹកចិត្តតាមក្តាខៀនប្រចាំថ្ងៃដូចដើម។ ដោយឡែក ភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តតាមគោលការណ៍របស់ក្រុមហ៊ុន និងតាមច្បាប់ស្តីពីការងារ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជា

THE ARBITRATION COUNCIL

ឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី ១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន គួ តាយ ហ័រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន លេខ ៥១១ ក.ប/អក/វក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃព្រហស្បតិ៍ ៤កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់ភាគីកម្មករនិយោជិត ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការទាមទារនូវលក្ខខណ្ឌការងារចំនួន ៤ចំណុច។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះរួចមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងបានធ្វើការផ្សះផ្សានៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នានោះទេ។ ចំណុចមិនសះជា ចំនួន ៤ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២១ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន គួ តាយ ហ័រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន លេខ ៥១១ ក.ប/អក/វក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើករណីមិនសះជានេះ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង ២ និង ០០ នាទីរសៀល។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ដើម្បីគោរពតាមវិធានការសុខាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសការរក្សាគម្លាតសុវត្ថិភាព ក្រុមអាជ្ញាកណ្តាលធ្វើសវនាការអនឡាញ ដោយប្រើប្រព័ន្ធហ្ស៊ូម (zoom) និងបន្ទប់សវនាការត្រូវបានបែងចែករវាងភាគីនៃវិវាទ និងក្រុមអាជ្ញាកណ្តាល។ នៅក្នុងសវនាការ ភាគីទាំងពីរមិនមានការជំទាស់ចំពោះនីតិវិធី និងមធ្យោបាយធ្វើសវនាការរបស់ក្រុមអាជ្ញាកណ្តាលនោះទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមស្វែករកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ៤ចំណុចនេះ និងបានផ្សះផ្សាលើចំណុចវិវាទបន្ថែមទៀត ហើយភាគីកម្មករនិយោជិតបានសម្រេចដកចំណុចវិវាទទី៤ ចេញពីការទាមទារនេះ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាចំណុចវិវាទដែលនៅសល់ ចំនួន ៣ចំណុច គឺចំណុចវិវាទទី១, ចំណុចវិវាទទី២ និងចំណុចវិវាទទី៣។

THE ARBITRATION COUNCIL

នៅក្នុងនីតិវិធីជ្រើសរើសប្រភេទសេចក្ដីបង្គាប់អាជ្ញាកណ្ដាល មុនចាប់ផ្ដើមសវនាការ ភាគីកម្មករនិយោជិតជ្រើសរើសសេចក្ដីបង្គាប់ជាប់កាតព្វកិច្ច ចំណែកភាគីនិយោជកជ្រើសរើសសេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច ដែលធ្វើឱ្យសេចក្ដីបង្គាប់នៅក្នុងសំណុំរឿងនេះ គឺជាសេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច យោងតាមនីតិវិធីនៃការជ្រើសរើសប្រភេទសេចក្ដីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល។ យ៉ាងណាមិញ នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានលើកឡើងថា ប្រការ ២ នៃអនុសញ្ញារួមរវាងក្រុមហ៊ុន ខេមបូស៊ីន ហ្វេងជីង ហ្គាមេន ខូអិលធីឌី (គួ តាយ ហ៉ រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន ជាមួយនឹងសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ខេមបូស៊ីន ហ្វេងជីង ហ្គាមេន ខូ អិលធីឌី (គួរ តាយ ហ៉ រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន បានកំណត់ថា ភាគីទាំងពីរយល់ព្រមជ្រើសរើសប្រភេទសេចក្ដីបង្គាប់ជាប់កាតព្វកិច្ច នៅពេលដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានកំណត់ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ ជាថ្ងៃផុតកំណត់ផ្ដល់ឯកសារ ឬភស្តុតាង និងថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ ឬភស្តុតាង។

ភាគីទាំងពីរបានឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្ដីបង្គាប់អាជ្ញាកណ្ដាល ពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើការរកឃើញនៃអង្គហេតុ និងភស្តុតាង ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិរបស់លោក ZHENG RONG ជានាយកសហគ្រាស គួ តាយ ហ៉ រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន ផ្ទេរសិទ្ធិជូនកញ្ញា វិញ សូស ម៉ាន់ និង អ្នកនាង វិញ ស៊ុយ យ៉ាវ ជាប្រធានរដ្ឋបាល តំណាងឱ្យនាយកក្រុមហ៊ុន ដែលមានសិទ្ធិ និងអំណាចពេញលេញក្នុងការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន គួ តាយ ហ៉ រ សេង ស៊ីន ហ្វេង ជីង(ខេមបូឌា)ហ្គាម៉ិន ចុះថ្ងៃព្រហស្បតិ៍ ១១កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៥ ត្រូវនឹងថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១។

២- លិខិតផ្ទេរសិទ្ធិរបស់លោក ZHENG RONG ជានាយកសហគ្រាស គួ តាយ ហ៉ រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន ផ្ទេរសិទ្ធិជូនលោក គិម ពេជ្រដា និងលោក តោ ដារិទ្ធ ជាមន្ត្រីការងារសមាគមរោងចក្រកាត់ដេរនៅកម្ពុជា តំណាងឱ្យនាយកក្រុមហ៊ុន ដែលមានសិទ្ធិ និងអំណាចពេញលេញក្នុងការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន គួ តាយ ហ៉ រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា)ហ្គាម៉ិន ចុះថ្ងៃព្រហស្បតិ៍ ១១កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៥ ត្រូវនឹងថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១។

THE ARBITRATION COUNCIL

៣- លិខិតលេខ ០១៧/២១ វិវាទ ស.ប.ក ចុះថ្ងៃសុក្រ ៩រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១ របស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា គោរពជូន លោកនាយកក្រុមហ៊ុន គួ តាយ ហ៊ូវ សេង ស៊ីន ហ្វេង ជីង(ខេមបូឌា)ហ្គា ម៉ិន ស្តីពីការស្នើជួបពិភាក្សា ដើម្បីដោះស្រាយបញ្ហាមួយចំនួនក្នុងក្រុមហ៊ុន។

៤- កំណត់ហេតុ ស្តីការប្រជុំចរចាដោះស្រាយវិវាទក្នុងក្រុមហ៊ុន គួ តាយ ហ៊ូវ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន ចុះថ្ងៃព្រហស្បតិ៍ ៨កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៥ ត្រូវនឹងថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១។

៥- កំណត់ហេតុ ស្តីការប្រជុំចរចាដោះស្រាយវិវាទក្នុងក្រុមហ៊ុន គួ តាយ ហ៊ូវ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន ចុះថ្ងៃអង្គារ ១៣រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៥ ត្រូវនឹងថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២១។

៦- កំណត់ហេតុ ស្តពីការសោកសួរព័ត៌មានតំណាងសហគ្រាស គួ តាយ ហ៊ូវ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១។

៧- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន គួ តាយ ហ៊ូវ សេង ស៊ីន ហ្វេង ជីង(ខេមបូឌា) ហ្គាម៉ិន ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១។

៨- លិខិតអញ្ជើញលេខ ១០៩៥ ក.ប/អ.ក/វ.ក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ របស់នាយកដ្ឋានវិវាទការងារ។

៩- ប័ណ្ណពន្ធប៉ាតង់ឆ្នាំ២០២១ ក្រុមហ៊ុន គួ តាយ ហ៊ូវ សេង ស៊ីន ហ្វេង ជីង(ខេមបូឌា) ហ្គាម៉ិន លេខ PTM២០២១០១៣៥៤៨ អពជ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១។

១០- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម លេខ MOC-៧០៨៩៦៥៣៧ ពណ.ចបព ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៤។

១១- លក្ខន្តិកៈក្រុមហ៊ុន គួ តាយ ហ៊ូវ សេង ស៊ីន ហ្វេង ជីង(ខេមបូឌា)ហ្គាម៉ិន បានតម្កល់ទុកលេខ ០៣៨៧/២០១៤ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម។

១២- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន គួ តាយ ហ៊ូវ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន ចុះទិដ្ឋាការ លេខ ២២៧ កប/អក/ អធក ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩ ដោយប្រធាននាយកដ្ឋានអធិការកិច្ចការងារ។

១៣- អនុសញ្ញារួម រវាងក្រុមហ៊ុន ខេមបូស៊ីន ហ្វេង ជីង ហ្គាមេន ខូអិលធីឌី(គួ តាយ ហ៊ូវ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា)ហ្គាម៉ិន) ជាមួយនិង សហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ខេមបូស៊ីន ហ្វេង ជីង ហ្គាមេន ខូអិលធីឌី(គួ តាយ ហ៊ូវ សេង ស៊ីន ហ្វេង ជីង(ខេមបូឌា)ហ្គាម៉ិន ) ចុះបញ្ជីលេខ ០០២កប/អក/វក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ ដោយប្រធាននាយកដ្ឋានវិវាទការងារស្តីទី។

១៤- ប័ណ្ណទំនាក់ទំនង របស់ក្រុមហ៊ុន គួ តាយ ហ៊ូវ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន។

១៥- តារាងលុយរង្វាន់ប្រចាំថ្ងៃ សម្រាប់ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១, ០៨ ខែមិថុនា ឆ្នាំ២០២១, ១១ ខែមិថុនា ឆ្នាំ២០២១, ១៥ ខែមិថុនា ឆ្នាំ២០២១, ១៩ ខែមិថុនា ឆ្នាំ២០២១, ២៣ ខែមិថុនា ឆ្នាំ២០២១, ២៦ ខែមិថុនា ឆ្នាំ២០២១, ៣០ ខែមិថុនា ឆ្នាំ២០២១, ០៣ ខែកក្កដា ឆ្នាំ២០២១។

THE ARBITRATION COUNCIL

១៦- តារាងលុយរង្វាន់ដេរផ្ទរស្លាយ របស់ក្រុមហ៊ុន គួ តាយ ហ៉ រ សេង ស៊ីន ហ្វេង ជីង(ខេមបូឌា)ហ្គាម៉ិន។

១៧- បញ្ជីបើកប្រាក់ខែសម្រាប់ខែមិថុនា ឆ្នាំ២០២១ (Line1, Line2, Line3, Line7, Line8, Line10, Line11, Line12, Line13, Line15, Line16, ផ្នែកគុកាត់, ឃ្លាំង១១, ឃ្លាំង២២, ផ្នែកអ៊ុត, ផ្នែកត្រួតពិនិត្យគុណភាព, ផ្នែកវេចខ្ចប់, ផ្នែកOffice។

១៨- តារាងលុយរង្វាន់សរុបសម្រាប់ Line5 ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២១, ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២១, ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១, ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១, ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២១។

១៩- តារាងលុយរង្វាន់សរុបសម្រាប់ផ្ទរស្លាយ សម្រាប់ Line5 នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ និង ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១។

២០- តារាងឈ្មោះកម្មករបានរង្វាន់តាមម៉ាស៊ីនខែមីនា ឆ្នាំ២០២១។

២១- តារាងប្រាក់ឈ្នួលកម្មករសម្រាប់ខែមីនា ឆ្នាំ២០២១ សម្រាប់ Line1, Line2, Line3, Line5 Line6, Line7, Line8, Line9, Line11, Line12, Line13, Line15, Line16។

២២- តារាងតម្លៃក្រុមដេរ របស់ក្រុមហ៊ុន គួ តាយ ហ៉ រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន។

២៣- តារាងតំឡើងប្រាក់ខែគោល ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ សម្រាប់ Line1, Line2, Line3, Line5 Line6, Line7, Line8, Line9, Line10, Line11, Line12, Line13, Line15, Line16។

២៤- តារាងតំឡើងប្រាក់ខែគោល ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ សម្រាប់ផ្នែកគុកាត់។

២៥- តារាងតំឡើងប្រាក់ខែគោល ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៥ សម្រាប់ផ្នែកវេចខ្ចប់។

២៦- តារាងតំឡើងប្រាក់ខែគោល ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ សម្រាប់ផ្នែកអ៊ុត។

២៧- តារាងតំឡើងប្រាក់ខែគោល ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ សម្រាប់ផ្នែកត្រួតពិនិត្យគុណភាព។

២៨- តារាងតំឡើងប្រាក់ខែគោល ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ សម្រាប់ផ្នែកឃ្លាំង២។

២៩- តារាងតំឡើងប្រាក់ខែគោល ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ សម្រាប់ផ្នែកឃ្លាំង១។

៣០- តារាងតំឡើងប្រាក់ខែគោល ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ សម្រាប់ផ្នែកតារាងតំឡើងប្រាក់ខែគោល ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ សម្រាប់ផ្នែកការិយាល័យ។

៣១- តារាងប្រាក់ឈ្នួលគោល របស់ប្រធានក្រុម។

៣២- តារាងប្រាក់ឈ្នួល អ្នកអត់បានរង្វាន់តាមម៉ាស៊ីន សម្រាប់ខែមីនា និងខែមិថុនា ឆ្នាំ២០២១។

៣៣- ប័ណ្ណទំនាក់ទំនង របស់ក្រុមហ៊ុន គួ តាយ ហ៉ រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន។

៣៤- សារណែនាំសម្រាប់សមាជិក អំពីការអនុវត្តសេចក្តីណែនាំលេខ ០៤៣/២១ ក.ប/ស.ជ.ណ.ន.ខ.វ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ របស់សមាគមកាត់ដេរនៅកម្ពុជា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១។

THE ARBITRATION COUNCIL

៣៥- សេចក្តីណែនាំលេខ ០៤៣/២១ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការបើកប្រាក់ឈ្នួលដើមខែមេសា និងប្រាក់ឧបត្ថម្ភបន្ថែមរបស់រោងចក្រ សហគ្រាស សិប្បកម្ម និងក្រុមហ៊ុន ដល់កម្មករនិយោជិតក្នុងអំឡុងពេលនៃការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ ។

៣៦- កិច្ចព្រមព្រៀងប្តូរថ្ងៃឈប់សម្រាក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់ក្រុមហ៊ុន គួ តាយ ហ័រ សេង ស៊ីន ហ្វេង ជីង(ខេមបូឌា)ហ្គាមិន។

៣៧- បញ្ជីបើកប្រាក់ខែសម្រាប់ខែមេសា ឆ្នាំ២០២១ (Line1, Line2, Line3, Line5, Line6, Line7, Line8, Line9, Line10, Line11, Line12, Line13, Line15, Line16, ផ្នែកតុកាត់, ឃ្លាំង១១, ឃ្លាំង ២២, ផ្នែកអ៊ុត, ផ្នែកត្រួតពិនិត្យគុណភាព, ផ្នែកវេចខ្ចប់, ផ្នែកOffice)។

៣៨- កម្មវិធីចែកអង្ករទៅកម្មករទាំងអស់ដែលបំពេញការងារនៅក្រុមហ៊ុន គួ តាយ ហ័រ សេង ស៊ីន ហ្វេង-ជីង (ខេមបូឌា)ហ្គាមិន។

៣៩- សេចក្តីសម្រេចលេខ ៤៩ សសរ ចុះថ្ងៃពុធ ៣កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ ។

៤០- សេចក្តីសម្រេចលេខ ៥៤ សសរ ចុះថ្ងៃចន្ទ ១៥កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ ។

៤១- សេចក្តីសម្រេចលេខ ១០០/២១ សសរ ចុះថ្ងៃពុធ ៩រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ ស្តីពីការដាក់ចេញវិធានការរដ្ឋបាលសម្រាប់ភូមិសាស្ត្ររាជធានីភ្នំពេញ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ ដោយបែងចែកជា "តំបន់ក្រហម" "តំបន់លឿងទុំ" និង "តំបន់លឿង" ។

៤២- សេចក្តីសម្រេចលេខ ១០៤/២១ សសរ ចុះថ្ងៃអង្គារ ១៥រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ ស្តីពីការដាក់ចេញវិធានការរដ្ឋបាលបន្ត សម្រាប់ភូមិសាស្ត្ររាជធានីភ្នំពេញ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ ដោយបែងចែកជា "តំបន់ក្រហម" "តំបន់លឿងទុំ" និង "តំបន់លឿង" ។

៤៣- សេចក្តីសម្រេចលេខ ១១១/២១ សសរ ចុះថ្ងៃពុធ ៨កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១ ស្តីពីការដាក់ចេញវិធានការរដ្ឋបាលបន្ត សម្រាប់ភូមិសាស្ត្ររាជធានីភ្នំពេញ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ ។

៤៤- បញ្ជីបើកប្រាក់ខែសម្រាប់ខែឧសភា ឆ្នាំ២០២១ (Line1, Line2, Line3, Line5, Line6, Line7, Line8, Line9, Line10, Line11, Line12, Line13, Line15, Line16, ផ្នែកតុកាត់, ឃ្លាំង១១, ឃ្លាំង ២២, ផ្នែកអ៊ុត, ផ្នែកត្រួតពិនិត្យគុណភាព, ផ្នែកវេចខ្ចប់, ផ្នែកOffice)។

THE ARBITRATION COUNCIL

៤៥- លិខិតចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ របស់ក្រុមហ៊ុន គួ តាយ ហ៉រ សេង ស៊ីន ហ្សេង ជីង(ខេមបូឌា) ហ្គាម៉ិន គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសារណាការពារ របស់ក្រុមហ៊ុន គួ តាយ ហ៉រ សេង ស៊ីន ហ្សេង ជីង (ខេមបូឌា) ហ្គាម៉ិន។

៤៦- តារាងលុយរង្វាន់លើកទឹកចិត្តជួរស្តាយប្រចាំខែកុម្ភៈ ឆ្នាំ២០២១។

៤៧- តារាងលុយរង្វាន់លើកទឹកចិត្តជួរស្តាយប្រចាំខែមករា ឆ្នាំ២០២១។

៤៨- តារាងលុយរង្វាន់ប្រចាំថ្ងៃ សម្រាប់ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២១ ចំពោះ Line6 ករណីអត់ផ្ទាំងក្រណាត់ ថ្ងៃទី១៦ កាត់ចំនួន ២ម៉ោង។

៤៩- តារាងលុយរង្វាន់ប្រចាំថ្ងៃ សម្រាប់ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២១ ចំពោះ Line5 ករណីជួរស្តាយ។

៥០- តារាងលុយរង្វាន់ក្តារខៀន ប្រចាំខែ កុម្ភៈ ឆ្នាំ២០២១, មីនា ឆ្នាំ២០២១, មិថុនា ឆ្នាំ២០២១, កក្កដា ឆ្នាំ២០២១ របស់ក្រុមហ៊ុន គួ តាយ ហ៉រ សេង ស៊ីន ហ្សេង ជីង (ខេមបូឌា) ហ្គាម៉ិន។

៥១- តារាងលុយរង្វាន់ប្រចាំថ្ងៃ(ចំនួនកំណត់ជាគោល 3.16 Pcs) សម្រាប់ Line5 ពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២១, ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១, ពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១, ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២១។

៥២- តារាងលុយរង្វាន់ប្រចាំថ្ងៃ(ចំនួនកំណត់ជាគោល 2 Pcs) សម្រាប់ Line6 ពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២១, ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១, ពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១, ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២១។

៥៣- តារាងលុយរង្វាន់ប្រចាំថ្ងៃ(ចំនួនកំណត់ជាគោល 3.16 Pcs) សម្រាប់ Line7 ពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២១, ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១, ពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១។

៥៤- តារាងលុយរង្វាន់ប្រចាំថ្ងៃ(ចំនួនកំណត់ជាគោល 6.6 Pcs) សម្រាប់ Line8 ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២១, ពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១, ពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១, ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១។

៥៥- តារាងលុយរង្វាន់ប្រចាំថ្ងៃ(ចំនួនកំណត់ជាគោល 6.4 Pcs) សម្រាប់ Line8 ពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២១, ពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១, ពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១, ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១។

៥៦- តារាងលុយរង្វាន់ប្រចាំថ្ងៃ(ចំនួនកំណត់ជាគោល 2.3 Pcs) សម្រាប់ Line5 ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២១, ពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១, ពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១។

THE ARBITRATION COUNCIL

៥៧- តារាងលុយរង្វាន់ប្រចាំថ្ងៃ(ចំនួនកំណត់ជាគោល 2.63 Pcs) សម្រាប់ Line5 ពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២១។

៥៨- តារាងលុយរង្វាន់ប្រចាំថ្ងៃ(ចំនួនកំណត់ជាគោល 3.45 Pcs) សម្រាប់ Line6 ពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២១។

៥៩- តារាងលុយរង្វាន់ប្រចាំថ្ងៃ(ចំនួនកំណត់ជាគោល 2 Pcs) សម្រាប់ Line6 ពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១, ពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១, ពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២១, ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២១។

៦០- តារាងលុយរង្វាន់ប្រចាំថ្ងៃ(ចំនួនកំណត់ជាគោល 1.58 Pcs) សម្រាប់ Line7 ពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២១, ពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១, ពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១, ពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២១។

៦១- តារាងលុយរង្វាន់ប្រចាំថ្ងៃ(ចំនួនកំណត់ជាគោល 3.16 Pcs) សម្រាប់ Line7 ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២១។

៦២- តារាងលុយរង្វាន់ប្រចាំថ្ងៃ(ចំនួនកំណត់ជាគោល 3.45 Pcs) សម្រាប់ Line8 ពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២១។

៦៣- តារាងលុយរង្វាន់ប្រចាំថ្ងៃ សម្រាប់ Line8 ពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១, ពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២១, ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២១, ពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ ដល់ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២១។

៦៤- តារាងលុយរង្វាន់ប្រចាំថ្ងៃ សម្រាប់ Line5 ធ្វើនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២១ , ៣០ ខែមិថុនា ឆ្នាំ២០២១, ២៦ ខែមិថុនា ឆ្នាំ២០២១, ២៣ ខែមិថុនា ឆ្នាំ២០២១, ១៩ ខែមិថុនា ឆ្នាំ២០២១, ១៥ ខែមិថុនា ឆ្នាំ២០២១, ១១ ខែមិថុនា ឆ្នាំ២០២១, ០៨ ខែមិថុនា ឆ្នាំ២០២១, ០៤ ខែមិថុនា ឆ្នាំ២០២១។

៦៥- តារាងលុយរង្វាន់ប្រចាំថ្ងៃ សម្រាប់ Line6 ធ្វើនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១, ២៥ ខែមិថុនា ឆ្នាំ២០២១, ១៩ ខែមិថុនា ឆ្នាំ២០២១, ១៥ ខែមិថុនា ឆ្នាំ២០២១។

៦៦- តារាងលុយរង្វាន់ប្រចាំថ្ងៃ សម្រាប់ Line7 ធ្វើនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១, ២៩ ខែមិថុនា ឆ្នាំ២០២១, ០៣ ខែកក្កដា ឆ្នាំ២០២១។

៦៧- តារាងលុយរង្វាន់ប្រចាំថ្ងៃ សម្រាប់ Line8 ធ្វើនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១, ២២ ខែមិថុនា ឆ្នាំ២០២១, ២៥ ខែមិថុនា ឆ្នាំ២០២១, ២៩ ខែមិថុនា ឆ្នាំ២០២១, ០២ ខែកក្កដា ឆ្នាំ២០២១ ។

៦៨- តារាងលុយរង្វាន់ប្រចាំថ្ងៃ សម្រាប់ Line5 ធ្វើនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២១, ០៧ ខែកក្កដា ឆ្នាំ២០២១, ១០ ខែកក្កដា ឆ្នាំ២០២១, ១៤ ខែកក្កដា ឆ្នាំ២០២១, ១៧ ខែកក្កដា ឆ្នាំ២០២១

THE ARBITRATION COUNCIL

២១ ខែកក្កដា ឆ្នាំ២០២១, ២៤ ខែកក្កដា ឆ្នាំ២០២១, ២៨ ខែកក្កដា ឆ្នាំ២០២១, ៣១ ខែកក្កដា ឆ្នាំ២០២១, ០៤ ខែសីហា ឆ្នាំ២០២១។

៦៩- តារាងលុយរង្វាន់ប្រចាំថ្ងៃ សម្រាប់ Line6 ធ្វើនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១, ១៩ ខែកក្កដា ឆ្នាំ២០២១, ២៣ ខែកក្កដា ឆ្នាំ២០២១, ៣០ ខែកក្កដា ឆ្នាំ២០២១, ០៤ ខែសីហា ឆ្នាំ២០២១។

៧០- តារាងលុយរង្វាន់ប្រចាំថ្ងៃ សម្រាប់ Line7 ធ្វើនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២១, ១៣ ខែកក្កដា ឆ្នាំ២០២១, ១៧ ខែកក្កដា ឆ្នាំ២០២១, ២១ ខែកក្កដា ឆ្នាំ២០២១,២៤ ខែកក្កដា ឆ្នាំ២០២១, ២៨ ខែកក្កដា ឆ្នាំ២០២១, ៣១ ខែកក្កដា ឆ្នាំ២០២១, ០៤ ខែសីហា ឆ្នាំ២០២១។

៧១- តារាងលុយរង្វាន់ប្រចាំថ្ងៃ សម្រាប់ Line8 ធ្វើនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១, ០៩ ខែកក្កដា ឆ្នាំ២០២១, ១៣ ខែកក្កដា ឆ្នាំ២០២១, ១៦ ខែកក្កដា ឆ្នាំ២០២១, ២០ ខែកក្កដា ឆ្នាំ២០២១, ២៣ ខែកក្កដា ឆ្នាំ២០២១, ២៧ ខែកក្កដា ឆ្នាំ២០២១, ៣០ ខែកក្កដា ឆ្នាំ២០២១, ០៣ ខែសីហា ឆ្នាំ២០២១។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតលេខ ០៣០/២១ ស.ប.ក/វិវាទ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ របស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ស្តីពីការចាត់តាំងលោក ស៊ាង យ៉ូត ជាមន្ត្រីដោះស្រាយវិវាទដើម្បីអមសម្របសម្រួលលើករណីដោះស្រាយវិវាទ ក្រុមហ៊ុន គួ តាយ ហ័រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា)ហ្គាម៉ិន។

២- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមលេខ ០០៣/២១ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ របស់នាយកដ្ឋានវិវាទការងារ។

៣- ពាក្យបណ្តឹង ចុះថ្ងៃអង្គារ ១៣កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១ របស់តំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន គួ តាយ ហ័រ សេង ស៊ីន ហ្វេង ជីង(ខេមបូឌា)ហ្គាម៉ិន គោរពជូន ប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីការស្នើជួយអន្តរាគម ឱ្យនិយោជកដោះស្រាយនូវការទាមទាររបស់កម្មករនិយោជិត។

៤- លិខិតលេខ ០៥០/២១ ក.ប/វក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន គួ តាយ ហ័រ សេង ស៊ីន ហ្វេង ជីង(ខេមបូឌា)ហ្គាម៉ិន ជាអង្គការវិជ្ជាជីវៈមួយត្រូវបានចុះបញ្ជីនៅនាយកដ្ឋានវិវាទការងារ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ។

៥- វិញ្ញាបនបត្របញ្ជាក់ពីភាពជាតំណាងបំផុត របស់សហជីពប្រជាធិបតេយ្យកម្មករ នៃក្រុមហ៊ុន ខេមបូ ស៊ីន ហ្វេង ជីង ហ្គាមេន ខូ អិលធីឌី លេខ ៦០៥ ក.ប/វ.ប.វ.ក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨។

៦- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈសហជីពប្រជាធិបតេយ្យកម្មករ នៃក្រុមហ៊ុន គួ តាយ ហ័រ សេង ស៊ីន ហ្វេង ជីង(ខេមបូឌា)ហ្គាម៉ិន លេខ ១១៦/២១ ក.ប/វ.ប.វ.ក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១។

THE ARBITRATION COUNCIL

៧- ពាក្យស្នើសុំបញ្ជាក់ភាពជាតំណាងបំផុត ចុះថ្ងៃចន្ទ ៥កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ របស់ឈ្មោះ អ៊ឹម សុភាព គោរពជូន ឯកឧត្តម រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីសំណើសុំបញ្ជាក់ភាពជាតំណាងបំផុត របស់សហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន គួ តាយ ហ៉រ សេង ស៊ីន ហ្វេង ជឹង(ខេមបូឌា) ហ្គាម៉ិន។

៨- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៃក្រុមហ៊ុន គួ តាយ ហ៉រ សេង ស៊ីន ហ្វេង ជឹង (ខេមបូឌា) ហ្គាម៉ិន ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១។

៩- អនុសញ្ញារួម រវាងក្រុមហ៊ុន ខេមបូស៊ីន ហ្វេង ជឹង ហ្គាមេន ខូអិលធីឌី (គួ តាយ ហ៉រ សេង ស៊ីន ហ្វេង ជឹង (ខេមបូឌា) ហ្គាម៉ិន) ជាមួយនិងសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ខេមបូ-ស៊ីន ហ្វេង ជឹង ហ្គាមេន ខូអិលធីឌី(គួ តាយ ហ៉រ សេង ស៊ីន ហ្វេង ជឹង(ខេមបូឌា) ហ្គាម៉ិន) ចុះបញ្ជីលេខ ០០២ កប/អក/វក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ ដោយប្រធាននាយកដ្ឋានវិវាទការងារស្តីទី។

១០- បង្កាន់ដៃបើកប្រាក់ឈ្នួល។

១១- លិខិតលេខ ០៥២/២១ សបក/វិវាទ ចុះថ្ងៃអង្គារ ១រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ របស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ស្តីពីសារណាករណីវិវាទសំណុំរឿងលេខ ០១៥/២១ គួ តាយ ហ៉រ សេង ស៊ីន ហ្វេង ជឹង(ខេមបូឌា)ហ្គាម៉ិន។

១២- សេចក្តីណែនាំ លេខ ០៤៣/២១ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការបើកប្រាក់ឈ្នួលដើមខែមេសា និងប្រាក់ឧបត្ថម្ភបន្ថែមរបស់រោងចក្រ សហគ្រាស សិប្បកម្ម និងក្រុមហ៊ុន ដល់កម្មករនិយោជិតក្នុងអំឡុងពេលនៃការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩។

១៣- សេចក្តីជូនដំណឹងលេខ ០២២/២១ ក.ប/ស.ជ.ណ.ខ.ល ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២១ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការចូលធ្វើការឡើងវិញ និងការបើកប្រាក់ឈ្នួលរបស់បងប្អូនកម្មករនិយោជិតនៅតាមរោងចក្រ សហគ្រាស ដែលបើកដំណើរការឡើងវិញក្រោយការបញ្ចប់វិធានការបិទខ្ទប់។

១៤- តារាងលុយរង្វាន់ប្រចាំថ្ងៃ(ចំនួនកំណត់ជាគោល 7.10 Pcs) សម្រាប់ Line8 សម្រាប់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ របស់ក្រុមហ៊ុន គួ តាយ ហ៉រ សេង ស៊ីន ហ្វេង ជឹង(ខេមបូឌា)ហ្គាម៉ិន។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន គួ តាយ ហ៉រ សេង ស៊ីន ហ្វេង ជឹង (ខេមបូឌា)ហ្គាម៉ិន លេខ ៥១១ ក.ប/អក/វក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៃក្រុមហ៊ុន គួ តាយ ហ៉រ សេង ស៊ីន ហ្វេង ជឹង(ខេមបូឌា) ហ្គាម៉ិន ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១។

THE ARBITRATION COUNCIL

៣- វិញ្ញាបនបត្របញ្ជាក់ពីភាពជាតំណាងបំផុត របស់សហជីពប្រជាធិបតេយ្យកម្មករ នៃក្រុមហ៊ុន ខេមបូ ស៊ីន ហ្វេង ជីង ហ្គាមេន ខូ អិលធីឌី លេខ ៦០៥ ក.ប/ វ.ប.វ.ក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៨៣ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ៤កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៨៤ កប/អក/វក/លកអ. ចុះថ្ងៃ ព្រហស្បតិ៍ ៤កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន គួ តាយ ហ័រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន គឺជាក្រុមហ៊ុនដែលមានសកម្មភាព ផ្នែកកាត់ដេរ និងមានដួលកម្មករនិយោជិតសរុបចំនួន ៦២០នាក់។ *(យោងតាមរបាយការណ៍ស្តីពី ការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន គួ តាយ ហ័រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន លេខ ៥១១ ក.ប/អក/វក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១)*
- នាយកដ្ឋានវិវាទការងារ បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិត ក្នុងការដោះស្រាយ វិវាទការងាររួម លេខ ០០៣/២១ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ ដែលមានឈ្មោះកម្មករនិយោជិត ចំនួន ៣នាក់ ៖ ១. អ៊ឹម សុភាព, ២. ខឿន វដ្ឋា និង ៣. ស៊ន់ យាប។
- វិញ្ញាបនបត្របញ្ជាក់ពីភាពតំណាងបំផុត របស់សហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ខេមបូ ស៊ីង ហ្វេង ជីង ហ្គាមេន ខូ អិលធិឌី លេខ១១២១៧០២០០ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៨។ យោង តាមលិខិតទទួលស្គាល់ថ្នាក់ដឹកនាំសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន គួ តាយ ហ័រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន លេខ ០៥០/២១ ក.ប/វ.ក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១ គឺមានឈ្មោះ លោកស្រី អ៊ឹម សុភាព ជាប្រធាន, លោក ខឿន វដ្ឋា ជាអនុប្រធាន, កញ្ញា ស៊ន់ យាប ជាលេខាធិការ។
- អនុសញ្ញារួមរវាងក្រុមហ៊ុន ខេមបូ ស៊ីង ហ្វេង ជីង ហ្គាមេន ខូ អិលធិឌី (គួ តាយ ហ័រ សេង ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន) និងសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុនក្រុមហ៊ុនខេមបូ ស៊ីង ហ្វេង ជីង ហ្គាមេន ខូ អិលធិឌី (គួ តាយ ហ័រ សេង ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន) ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩។
- កថាខណ្ឌទី៣ ប្រការ ២ អនុសញ្ញារួមរវាងក្រុមហ៊ុន ខេមបូស៊ីន ហ្វេងជីង ហ្គាមេន ខូ អិលធីឌី (គួ តាយ ហ័រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន ជាមួយនឹងសហជីពប្រជាធិបតេយ្យកម្មករ នៃក្រុមហ៊ុន ខេមបូស៊ីន ហ្វេងជីង ហ្គាមេន ខូ អិលធីឌី (គួរ តាយ ហ័រ សេង ស៊ីន ហ្វេង ជីង (ខេមបូ

THE ARBITRATION COUNCIL

ឌ) ហ្គាម៉ិន ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ ចែងថា ៖ "*...ហើយបើសិនជាវិវាទត្រូវដោះស្រាយរហូតក្រុមប្រឹក្សាអាជ្ញាកណ្តាល ភាគីទាំងពីរយល់ព្រមជ្រើសរើសយកសេចក្តីបង្គាប់ចងកាតព្វកិច្ច*"។

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ និងរក្សាអត្ថប្រយោជន៍ដែលបានបាត់បង់ ដូចជា ប្រាក់រង្វាន់តាមក្តារខៀន, ប្រាក់រង្វាន់តាមម៉ាស៊ីន, ប្រាក់រង្វាន់ដេរស៊ីបុង និងប្រាក់រង្វាន់ដេរដូរស្ពាយ ដូចដើមវិញ**

- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ប្រាក់រង្វាន់តាមម៉ាស៊ីន និងប្រាក់ដេរស៊ីបុង គឺជាប្រាក់រង្វាន់តែមួយទេ។ ហេតុនេះ ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកផ្តល់ និងរក្សាប្រាក់រង្វាន់តាមក្តារខៀន, ប្រាក់ឈ្នួលតាមបរិមាណផលិតផល (ប្រាក់ដេរស៊ីបុង) និងប្រាក់រង្វាន់ដេរប្តូស្ពាយ ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ ជូនកម្មករនិយោជិត។

**ក. ប្រាក់រង្វាន់តាមក្តារខៀន**

- ភាគីទាំងពីរទទួលស្គាល់ថា៖
  - ចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៧ និយោជកបានអនុវត្តការផ្តល់ជូនប្រាក់រង្វាន់តាមក្តារខៀនដល់ក្រុមនីមួយៗ ដោយកម្មករនិយោជិតម្នាក់ៗអាចទទួលបានប្រាក់រង្វាន់នេះចំនួន ២០០០ ទៅ ១៦០០០រៀល ក្នុងមួយថ្ងៃ ហើយនិយោជកគិតប្រាក់រង្វាន់នេះជូនកម្មករនិយោជិតជារៀងរាល់ថ្ងៃ នៅពេលដែលកម្មករនិយោជិតធ្វើការដល់គោលដៅកំណត់ និងបើកជូនកម្មករនិយោជិតមួយខែម្តង។
  - ចាប់ពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១ និយោជកបានកែប្រែការអនុវត្តផ្តល់ប្រាក់រង្វាន់តាមក្តារខៀននេះ ដោយតម្រូវឱ្យកម្មករនិយោជិតធ្វើការឱ្យដល់គោលដៅកំណត់រយៈពេល ៣ថ្ងៃ ជាប់គ្នា ទើបទទួលបានប្រាក់រង្វាន់នេះ។ បើសិនជាកម្មករនិយោជិតធ្វើការមិនដល់គោលដៅនៅថ្ងៃណាមួយ ក្នុងចំណោមរយៈពេលកំណត់ ៣ថ្ងៃខាងលើ កម្មករនិយោជិតនឹងមិនអាចទទួលបានប្រាក់រង្វាន់ទាំង ៣ថ្ងៃ ជាប់គ្នាតែម្តង។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - កម្មករនិយោជិតធ្លាប់ធ្វើការសាកល្បងជាមួយការអនុវត្តថ្មីរបស់និយោជកហើយ ប៉ុន្តែកម្មករនិយោជិតមិនអាចធ្វើការដល់គោលដៅកំណត់ និងមិនអាចទទួលបានរង្វាន់នោះទេ ពីព្រោះពេលខ្លះ មានសមាជិកក្រុមអវត្តមាន និងនៅពេលខ្លះម៉ាស៊ីនខូច។
  - ការអនុវត្តថ្មីរបស់និយោជកធ្វើឱ្យបាត់បង់អត្ថប្រយោជន៍របស់កម្មករនិយោជិត ហើយកម្មករនិយោជិតបានធ្វើកូដកម្មកាលខែមិថុនា ឆ្នាំ២០២១ ដែលជាការបង្ហាញឆន្ទះរបស់កម្មករនិយោជិត អំពីការមិនទទួលយកការអនុវត្តថ្មីរបស់និយោជក។
  - មាត្រា ១៣ នៃច្បាប់ស្តីពីការងារ បញ្ជាក់ថា ច្បាប់នេះ មិនមែនជាឧបសគ្គចំពោះការផ្តល់ផលប្រយោជន៍ដែលប្រសើរជាងច្បាប់ឡើយ ប៉ុន្តែអ្វីដែលធ្វើឱ្យបាត់បង់អត្ថប្រយោជន៍របស់កម្មករនិយោជិត គឺនិយោជកត្រូវធ្វើការកែលម្អឱ្យបានប្រសើរឡើងវិញ។
  - ចំពោះការអនុវត្តចាស់ និយោជកបានអនុវត្តផ្តល់ជូនកម្មករនិយោជិតតាំងពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៧ ហើយនិយោជកមិនបានផ្តល់ព័ត៌មានជូនអធិការការងារអំពីការផ្លាស់ប្តូរទៅអនុវត្តគោលការណ៍ថ្មី នៃប្រាក់រង្វាន់តាមក្តារខៀននោះទេ។
- ភាគីនិយោជកមិនអាចផ្តល់ជូនតាមទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថា ៖

- ○ សម្រាប់ការអនុវត្តចាស់ គឺមានតែកម្មករនិយោជិតប្រមាណ ២០០នាក់ប៉ុណ្ណោះ ដែលទទួលបានប្រាក់រង្វាន់តាមក្តារខៀន។ ប៉ុន្តែ សម្រាប់ការអនុវត្តថ្មី កម្មករនិយោជិតទទួលបានប្រាក់រង្វាន់ច្រើនទាំងអស់គ្នា។
- ○ និយោជកមានភស្តុតាងបញ្ជាក់ថា កម្មករនិយោជិតប្រមាណ ៩០ ទៅ ១០០ ភាគរយ អាចធ្វើបានដល់គោលដៅ និងអាចទទួលបានប្រាក់រង្វាន់តាមការខៀនតាមការអនុវត្តថ្មីនេះ និងអាចទទួលបានប្រាក់រង្វាន់ច្រើនជាងមុន គឺចាប់ពី ៤០០០ រៀល ទៅ ៤២០០០រៀល ក្នុងមួយថ្ងៃ ដែលបង្ហាញថា ការអនុវត្តថ្មីគឺផ្តល់អត្ថប្រយោជន៍ឱ្យកម្មករនិយោជិតប្រសើរជាងមុន ហើយធ្វើឱ្យចង្វាក់ផលិតកម្មលែងមានការរាំងស្ទះដូចពីមុន។
- ○ នៅពេលមានសមាជិកក្រុមអវត្តមាន, ខូចម៉ាស៊ីន, ខ្វះក្រណាត់ ឬខ្វះអំបោះ និយោជកតែងតែបន្ថយចំនួនគោលដៅតាមសមាមាត្រនៃចំនួនកម្មករនិយោជិតនៃក្រុមនីមួយៗ និងតាមភាពជាក់ស្តែង ពីព្រោះបញ្ហាទាំងនេះជាបន្ទុករបស់និយោជក។

- ភាគីនិយោជកបានដាក់ឯកសារជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា ដូចខាងក្រោម ៖
  - ○ តារាងប្រាក់រង្វាន់សម្រាប់ថ្ងៃទី១៥ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ ដែលបង្ហាញថានៅថ្ងៃទី១៥ និយោជកបានកំណត់គោលដៅចំនួន ១៩៦០ សម្រាប់កម្មករនិយោជិតចំនួន ២៨នាក់ ធ្វើការក្នុងរយៈពេលចំនួន ១០ម៉ោង។ នៅថ្ងៃទី១៦ និយោជកបានកំណត់គោលដៅចំនួន ១២៦០ សម្រាប់រយៈពេលធ្វើការ ៦ម៉ោង និងមានកម្មករនិយោជិតធ្វើការចំនួន ៣០នាក់ ហើយនៅថ្ងៃទី១៧ និយោជកបានកំណត់គោលដៅចំនួន ២១០០ សម្រាប់រយៈពេលធ្វើការ ១០ម៉ោង និងមានកម្មករនិយោជិតធ្វើការចំនួន ៣០នាក់។
  - ○ តារាងប្រាក់រង្វាន់តាមក្តារខៀនដែលកម្មករនិយោជិតទទួលបានសម្រាប់ខែកុម្ភៈ, ខែមីនា, ខែមិថុនា និងខែកក្កដា ឆ្នាំ២០២១ ដែលបង្ហាញថា នៅពេលដែលនិយោជកអនុវត្តគោលការណ៍ថ្មីនៃប្រាក់រង្វាន់តាមក្តារខៀននៅខែមិថុនា និងខែកក្កដា ឆ្នាំ២០២១ កម្មករនិយោជិតនៅខ្សែចង្វាក់ផលិតកម្មលេខ ១, ២, ៥, ៧, ៩, ១០, ១១, ១៥, ១៦ ក្នុងចំណោមខ្សែចង្វាក់ផលិតកម្មសរុបចំនួន ១៤ ទទួលបានប្រាក់រង្វាន់តាមក្តារខៀនច្រើនជាង នៅពេលដែលនិយោជកអនុវត្តគោលការណ៍ចាស់នៃប្រាក់រង្វាន់តាមក្តារខៀននៅខែកុម្ភៈ និងខែមីនា ឆ្នាំ២០២១។

### ខ. ប្រាក់ឈ្នួលតាមបរិមាណផលិតផល (ប្រាក់ដេរស៊ីបុង)

- ភាគីទាំងពីរទទួលស្គាល់ថា ចាប់ពីឆ្នាំ២០១៤មក និយោជកអនុវត្តឱ្យកម្មករនិយោជិតធ្វើការទទួលបានប្រាក់ឈ្នួលតាមបរិមាណផលិតផល។ នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១ និយោជកបានជូនដំណឹងផ្ទាល់មាត់ទៅកម្មករនិយោជិត អំពីការចាប់ផ្តើមផ្លាស់ប្តូរឱ្យកម្មករនិយោជិតធ្វើការទទួលបានប្រាក់ឈ្នួលគោលប្រចាំខែវិញចំនួន ១៩២ដុល្លារអាមេរិក ក្នុងមួយខែ ដោយចាប់អនុវត្តពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - ○ ការផ្តល់ប្រាក់ឈ្នួលតាមបរិមាណផលិតផល គឺជាការអនុវត្តកន្លងមកតាំងពីឆ្នាំ២០១៤ ហើយ និយោជកបានរីកចម្រើនមករហូតព្រោះកម្មករនិយោជិតខិតខំធ្វើការ ដើម្បីទទួលបានប្រាក់ឈ្នួលច្រើន។

THE ARBITRATION COUNCIL

- ការផ្លាស់ប្តូរនេះនឹងធ្វើឱ្យកម្មករនិយោជិតលែងខិតខំធ្វើការ ព្រោះខិតខំប្រឹងប្រែងយ៉ាងណា ក៏កម្មករនិយោជិតទទួលបានតែប្រាក់ឈ្នួលចំនួន ១៩២ដុល្លារអាមេរិក ដូចកម្មករនិយោជិតដែលមិនខំប្រឹងដែរ។
- ការផ្លាស់ប្តូរនេះ ធ្វើឱ្យបាត់បង់អត្ថប្រយោជន៍របស់កម្មករនិយោជិត ពីព្រោះពីមុនមក កម្មករនិយោជិតតែងតែធ្វើការទទួលបានប្រាក់ឈ្នួលប្រមាណចំនួន ២០០ ទៅ ៣០០ ដុល្លារអាមេរិក ក្នុងមួយខែ។
- និយោជកអាចអនុវត្តគោលការណ៍ថ្មីបាន តែត្រូវបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតតាមចំនួនថ្ងៃដែលធ្វើបានដល់គោលដៅកំណត់នីមួយៗ។

- ភាគីនិយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថា ៖
  - និយោជកបានជូនដំណឹងអំពីការអនុវត្តថ្មីនេះ និងបានប្រជុំជាមួយកម្មករនិយោជិតនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១ និងចាប់អនុវត្តពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១។
  - ការអនុវត្តពីមុន ធ្វើឱ្យកម្មករនិយោជិតទទួលបានអត្ថប្រយោជន៍មិនស្មើគ្នា និងមិនចេះជួយគ្នានៅក្នុងក្រុម។
  - តាមការអនុវត្តចាស់ មានកម្មកនិយោជិតតែចំនួនជាង ២០០នាក់ប៉ុណ្ណោះ ក្នុងចំណោមកម្មករនិយោជិតចំនួន ៧០០នាក់ ដែលទទួលបានប្រាក់ឈ្នួលតាមបរិមាណផលិតផល ដោយនិយោជកមិនចាំបាច់បន្ថែមប្រាក់ឈ្នួលឱ្យគ្រប់ប្រាក់ឈ្នួលអប្បបរមា។
  - និយោជកបានបន្ថែមប្រាក់ចំនួន ២ ដុល្លារ ទៅ ៥ដុល្លារ ទៀត ពីលើប្រាក់ឈ្នួលគោលរបស់កម្មករនិយោជិតម្នាក់ៗ ដោយអាស្រ័យលើជំនាញ និងបទពិសោធន៍របស់គាត់ ហើយការអនុវត្តថ្មីនេះ ធ្វើឱ្យកម្មករនិយោជិតធ្វើការក្នុងល្បឿនស្មើគ្នា និងមិនស្ទះដល់ចង្វាក់ផលិតកម្ម។

## គ. ប្រាក់រង្វាន់ដេរប្តូរស្លាយ

- ភាគីទាំងពីរទទួលស្គាល់ថា ប្រាក់រង្វាន់ប្តូរស្លាយនេះ មានចែងនៅក្នុងអនុសញ្ញារួម។ នៅពេលដែលនិយោជកតម្រូវឱ្យកម្មករនិយោជិតប្តូរស្លាយដេរ និយោជកផ្តល់ប្រាក់រង្វាន់ដេរប្តូរស្លាយជូនកម្មករនិយោជិតចំនួន ៦ដុល្លារអាមេរិក។ ចាប់ពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១ និយោជកចាប់ផ្តើមបញ្ឈប់អនុវត្តផ្តល់ជូនប្រាក់រង្វាន់ដេរប្តូរស្លាយនេះ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា និយោជកមិនបានអនុវត្តតាមអនុសញ្ញារួម និងបានកាត់អត្ថប្រយោជន៍ប្រាក់រង្វាន់ដេរប្តូរស្លាយចំនួន ៦ដុល្លារអាមេរិក របស់កម្មករនិយោជិត។ នៅក្នុងអនុសញ្ញារួម មិនបានភ្ជាប់ប្រាក់ប្តូរស្លាយនេះជាមួយប្រាក់ឈ្នួលតាមបរិមាណផលិតផលនោះទេ។
- ភាគីនិយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតទេ ពីព្រោះកថាខណ្ឌទី៣ នៃប្រការ ៨ នៃអនុសញ្ញារួម គឺអនុវត្តចំពោះតែកម្មករនិយោជិតធ្វើការបានប្រាក់ឈ្នួលតាមបរិមាណផលិតផលតែប៉ុណ្ណោះ ប៉ុន្តែ បច្ចុប្បន្ននិយោជកលែងឱ្យកម្មករនិយោជិតធ្វើការទទួលបានប្រាក់ឈ្នួលតាមបរិមាណផលិតផលទៀតហើយ។ ហេតុនេះ កម្មករនិយោជិតមិនអាចទទួលបានប្រាក់រង្វាន់ដេរប្តូរស្លាយទៀតទេ។
- កថាខណ្ឌទី ៣ ប្រការ ៨ នៃអនុសញ្ញារួមរវាងក្រុមហ៊ុន ខេមបូស៊ីន ហ្វេងជីង ហ្គាមេន ខូ អិលធីឌី (គួ តាយ ហ័រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន ជាមួយនឹងសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ខេមបូស៊ីន ហ្វេងជីង ហ្គាមេន ខូ អិលធីឌី (គួរ តាយ ហ័រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា)

ហ្គាម៉ិន ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ ចែងថា ៖ *"ក្រុមហ៊ុនឯកភាពក្នុងការផ្ដល់ប្រាក់ម៉ោងដូរស្ដោយ ក្នុងមួយស្ដាយ ៦ដុល្លារ នៅពេលដែលមានការដូរស្ដោយ"*។

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្ដល់ប្រាក់ឈ្នួលសម្រាប់ខែមេសា ឆ្នាំ២០២១ ចាប់ពីថ្ងៃទី០១ រហូតដល់ថ្ងៃទី១៤ ចំនួន ១០០% និងចាប់ពីថ្ងៃទី១៥ រហូតដល់ថ្ងៃទី៣០ មេសាចំនួន ៥០% ដល់កម្មករនិយោជិត**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារឱ្យនិយោជកផ្ដល់ប្រាក់ឈ្នួលចំនួន ៥០ភាគរយ ជូនកម្មករនិយោជិត សម្រាប់ថ្ងៃទី១៥ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ ក្នុងអំឡុងពេលវិធានការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្ដាល។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - សេចក្ដីណែនាំលេខ ០៤៣ ក៏លើកទឹកចិត្តនិយោជកឱ្យផ្ដល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតតាមលទ្ធភាពផ្អែកលើស្មារតីមនុស្សធម៌ និងការសាមគ្គីក្នុងអំឡុងពេលបិទខ្ទប់ដែរ។
  - កម្មករនិយោជិតត្រូវចំណាយលើគ្រឿងឧបភោគបរិភោគ, បង់ថ្លៃប្រើប្រាស់ទឹកស្អាត, បង់ថ្លៃប្រើប្រាស់អគ្គិសនី និងបង់ថ្លៃផ្ទះជួល។
  - ក្រុមហ៊ុនផ្សេងៗដែលនៅជិតគ្នានោះ ដូចជា ក្រុមហ៊ុន ឌីន ហាន អេនជើប្រាយ, ក្រុមហ៊ុន ញូ អូរៀន និងក្រុមហ៊ុន សិន ចូវ បានផ្ដល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតចំនួន ៥០ភាគរយ។
  - និយោជកមិនបានផ្ដល់អង្ករជូនកម្មករនិយោជិតម្នាក់ចំនួន ១០គីឡូក្រាម សម្រាប់ខែមេសា ឆ្នាំ២០២១ទេ ការផ្ដល់ជូននេះ គឺនៅខែឧសភា ទេ។
- ភាគីនិយោជកមិនអាចផ្ដល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថា ៖
  - សេចក្ដីណែនាំរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ កំណត់ថានិយោជកអាចផ្ដល់ឱ្យតាមសមធម៌។
  - ស្ថានភាពហិរញ្ញវត្ថុក្រុមហ៊ុនផ្សេងគ្នា គឺខុសគ្នា ហេតុនេះ និយោជកមិនអាចផ្ដល់ជូនប្រាក់ឈ្នួលចំនួន ៥០ភាគរយ ដល់កម្មករនិយោជិតដូចក្រុមហ៊ុនផ្សេងនោះទេ។
  - និយោជកបានផ្ដល់អង្ករជូនកម្មករនិយោជិតម្នាក់ចំនួន ១០គីឡូក្រាម និងគ្រឿងឧបភោគផ្សេងទៀតរួចហើយ។

**ចំណុចវិវាទទី ៣ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្ដល់ប្រាក់ឈ្នួលចំនួន ១០០ភាគរយ សម្រាប់ខែឧសភា ឆ្នាំ២០២១ ជូនកម្មករនិយោជិត នៅក្នុងអំឡុងពេលនៃវិធានការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្ដាល**

- ភាគីទាំងពីរទទួលស្គាល់ថា ៖
  - ក្រុមហ៊ុន គួ តាយ ហ៊ា សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន គឺស្ថិតនៅសង្កាត់ស្ទឹងមានជ័យ ហើយត្រូវបានរាជរដ្ឋាភិបាលកំណត់ជាតំបន់ក្រហមត្រឹមថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១។
  - ក្រុមហ៊ុនចាប់ផ្ដើមបើកដំណើរការឡើងវិញ នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ ហើយកម្មករនិយោជិតដែលអាចមកធ្វើការបាន ទទួលបានប្រាក់ឈ្នួលវិញធម្មតា ប៉ុន្តែមានកម្មករនិយោជិត

THE ARBITRATION COUNCIL

មួយចំនួនដែលមានទីលំនៅ ឬទីសំណាក់ស្ថិតនៅក្នុងភូមិសាស្ត្រដែលត្រូវបានកំណត់ជាតំបន់ក្រហម មិនអាចមកធ្វើការបានរហូតដល់ថ្ងៃទី២៦ ឬទី២៧ ខែឧសភា ឆ្នាំ២០២១។

- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - រោងចក្របើកដំណើរការពេញលេញវិញ នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១។
  - កម្មករនិយោជិតខ្លះមានទីលំនៅ ឬទីសំណាក់នៅខេត្ត, ខ្លះមានទីលំនៅ ឬទីសំណាក់នៅក្នុងភូមិសាស្ត្រដែលត្រូវបានកំណត់ជាតំបន់ក្រហម និងខ្លះត្រូវធ្វើចត្តាឡីស័ក ដែលជាហេតុធ្វើឱ្យគាត់មិនអាចមកធ្វើការបាន។
- ភាគីនិយោជកមិនអាចផ្ដល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថា ៖
  - កម្មករនិយោជិតភាគច្រើនមានទីលំនៅ ឬទីសំណាក់មិនស្ថិតនៅក្នុងភូមិសាស្ត្រដែលត្រូវបានកំណត់ជាតំបន់ក្រហម ប៉ុន្តែពួកគាត់មិនបានមកធ្វើការនៅក្នុងអំឡុងពេលថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ទេ។ ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៧០០នាក់ មានកម្មករនិយោជិតតែចំនួនជាង ២០០ ទៅ ៣០០នាក់ប៉ុណ្ណោះ ដែលបានមកធ្វើការចាប់ពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ បញ្ហានេះធ្វើឱ្យនិយោជកមិនអាចផលិតទំនិញជូនអ្នកបញ្ជាទិញទាន់ពេលវេលា។
  - និយោជកបានផ្តល់អង្ករជូនកម្មករនិយោជិតរួចរាល់ហើយ។

## ហេតុផលនៃសេចក្តីសម្រេច ÷

### ការពិចារណាអំពីប្រភេទនៃសេចក្តីបង្គាប់សម្រាប់សំណុំរឿងនេះ ៖

នៅក្នុងនីតិវិធីជ្រើសរើសប្រភេទសេចក្តីបង្គាប់អាជ្ញាកណ្តាល មុនចាប់ផ្តើមសវនាការ ភាគីកម្មករនិយោជិតជ្រើសរើសសេចក្តីបង្គាប់ជាប់កាតព្វកិច្ច ចំណែកភាគីនិយោជកជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច ដែលធ្វើឱ្យសេចក្តីបង្គាប់នៅក្នុងសំណុំរឿងនេះ គឺជាសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ចយោងតាមនីតិវិធីនៃការជ្រើសរើសប្រភេទសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ យ៉ាងណាមិញ នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានលើកឡើងថា ប្រការ ២ នៃអនុសញ្ញារួមរវាងក្រុមហ៊ុន ខេមបូស៊ីន ហ្វេងជីង ហ្គាមេន ខូ អិលធីឌី (គួ តាយ ហ៉ រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន ជាមួយនឹងសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ខេមបូស៊ីន ហ្វេងជីង ហ្គាមេន ខូ អិលធីឌី (គួរ តាយ ហ៉ រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន បានកំណត់ថា ភាគីទាំងពីរយល់ព្រមជ្រើសរើសប្រភេទសេចក្តីបង្គាប់ជាប់កាតព្វកិច្ច នៅពេលដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើសេចក្តីបង្គាប់នៃសំណុំរឿងនេះជាប្រភេទសេចក្តីបង្គាប់ជាប់កាតព្វកិច្ច ឬជាប្រភេទសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច?

កថាខណ្ឌទី៣ ប្រការ ២ នៃអនុសញ្ញារួមរវាងក្រុមហ៊ុន ខេមបូស៊ីន ហ្វេងជីង ហ្គាមេន ខូ អិលធីឌី (គួ តាយ ហ៉ រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន ជាមួយនឹងសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ខេមបូស៊ីន ហ្វេងជីង ហ្គាមេន ខូ អិលធីឌី (គួរ តាយ ហ៉ រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ ចែងថា ៖ "*...ហើយបើសិនជាវិវាទត្រូវដោះស្រាយរហូត ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភាគីទាំងពីរយល់ព្រមជ្រើសរើសយកសេចក្តីបង្គាប់ចងកាតព្វកិច្ច*"។

យោងតាមកថាខណ្ឌទី៣ ប្រការ ២ នៃអនុសញ្ញារួមខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសង្កេតឃើញថា ភាគីនិយោជកព្រមព្រៀងនៅក្នុងអនុសញ្ញារួមរបស់ខ្លួន ជាមួយនឹងសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ខេមបូ

THE ARBITRATION COUNCIL

ស៊ីន ហ្វេងជីង ហ្គាមេន ខូ អិលធីឌី ក្នុងការជ្រើសរើសប្រភេទសេចក្តីបង្គាប់ជាប់កាតព្វកិច្ចនៅពេលមានវិវាទការងារមកដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ហើយភាគីទាំងសងខាងនៃសំណុំរឿងនេះ ក៏ជាភាគីទាំងសងខាងនៃអនុសញ្ញារួមខាងលើដែរ។

ហេតុនេះ យោងតាមកថាខណ្ឌទី៣ ប្រការ ២ នៃអនុសញ្ញារួមខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីទាំងពីរមានកាតព្វកិច្ចអនុវត្តទៅតាមខ្លឹមសារនៃអនុសញ្ញារួម ដែលបានព្រមព្រៀងក្នុងការជ្រើសរើសប្រភេទសេចក្តីបង្គាប់ជាប់កាតព្វកិច្ច នៅពេលដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។

សរុបមក សេចក្តីបង្គាប់នៃសំណុំរឿងនេះ គឺជាប្រភេទសេចក្តីបង្គាប់ជាប់កាតព្វកិច្ច។

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ និងរក្សាប្រាក់រង្វាន់តាមក្តារខៀន, ប្រាក់រង្វាន់ដេរស៊ីបុង (ប្រាក់ឈ្នួលតាមបរិមាណផលិតផល) និងប្រាក់រង្វាន់ដេរប្តូរស្ទាយ ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ ជូនកម្មករនិយោជិត**

**ក. ប្រាក់រង្វាន់តាមក្តារខៀន**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកប្រើប្រាស់សិទ្ធិចាត់ចែងក្នុងការផ្តល់ជូនប្រាក់រង្វាន់តាមក្តារខៀនជូនកម្មករនិយោជិតដោយស្របច្បាប់ និងសមហេតុផលដែរ ឬទេ?

មាត្រា ២ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា៖ *"...សហគ្រាសនីមួយៗ អាចមានគ្រឹះស្ថានច្រើន ហើយគ្រឹះស្ថាននីមួយៗនោះ មានប្រើមនុស្សមួយក្រុមធ្វើការរួមគ្នាក្នុងទីកន្លែងណាមួយជាប្រាជក ដូចជា ក្នុងរោងចក្រ រោងជាង ការដ្ឋាន។ល។ ក្រោមការគ្រប់គ្រងនិងដឹកនាំនៃនិយោជក..."*។

ក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថាមាត្រា ២ នៃច្បាប់ស្តីពីការងារខាងលើ មានន័យថា និយោជកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន ដរាបណាសិទ្ធិនេះ ត្រូវបានធ្វើឡើងដោយស្របច្បាប់ និងសមហេតុផល *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ៦២/០៦-ឃ្វីកស៊ូ ហេតុផលនៃចំណុចវិវាទទី៥, លេខ ១០៨/០៦-ទ្រីនុងហ្គាល គូម៉ាក់, លេខ ៣៣/០៧-ហ្គោលហ្វេម ហេតុផលនៃចំណុចវិវាទទី៣, លេខ ១១៩/០៩-អេស អិល ហេតុផលនៃចំណុច វិវាទទី៤ និងទី៥ និងលេខ ៣៣/១៣-ព្រលានយន្តហោះអន្តរជាតិសៀមរាបហេតុផលនៃចំណុចវិវាទទី ៦)*។

ម្យ៉ាងវិញទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ៖ *"និយោជកតាមរយៈការសម្រេចជាឯកតោភាគី អាចរៀបចំផែនការផ្តល់ប្រាក់រង្វាន់ផ្សេងៗ ក្រៅពីប្រាក់រង្វាន់ដែលកំណត់ក្នុងច្បាប់ការងារ ដើម្បីជំរុញ ឬលើកទឹកចិត្តកម្មករនិយោជិតខិតខំធ្វើឱ្យមានផលិតកម្មច្រើន ហើយប្រើពេលវេលាតិច"។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២៤/០៥-វ៉ារ វ៉ែល ហេតុផលនៃចំណុចវិវាទទី២, លេខ២០៣/១៣-តៃ ក៉ាង ត្រីនជីង ហេតុផលនៃចំណុចវិវាទទី១ និងលេខ ០២៩/១៥-ប្រ៊ីធីស អឺមើរីខិន ប៊ីប៊ែកខូ ខេមបូឌា ហេតុផលនៃចំណុចវិវាទទី៣ ទី៤ និងទី៥)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗខាងលើដែរ។

យោងតាមអង្គហេតុ ចាប់ពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១ និយោជកបានកែប្រែការអនុវត្តផ្តល់ប្រាក់រង្វាន់តាមក្តារខៀននេះ ដោយតម្រូវឱ្យកម្មករនិយោជិតធ្វើការឱ្យដល់គោលដៅកំណត់រយៈពេល ៣ថ្ងៃ ជាប់គ្នា ទើបទទួលបានប្រាក់រង្វាន់នេះ។ បើសិនជាកម្មករនិយោជិតធ្វើការមិនដល់គោលដៅនៅថ្ងៃណាមួយ ក្នុងចំណោមរយៈពេលកំណត់ ៣ថ្ងៃ ខាងលើ កម្មករនិយោជិតនឹងមិនអាចទទួលបានប្រាក់រង្វាន់ទាំង ៣ថ្ងៃ ជាប់គ្នាតែម្តង។ នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានលើកឡើងថា ការអនុវត្តគោលការណ៍ថ្មីនៃប្រាក់រង្វាន់តាមក្តារខៀន

THE ARBITRATION COUNCIL

របស់និយោជកដល់ក្រុមនីមួយៗ ធ្វើឱ្យបាត់បង់អត្ថប្រយោជន៍របស់កម្មករនិយោជិត ហើយកម្មករនិយោជិតមិនអាចធ្វើការដល់គោលដៅកំណត់ នឹងមិនអាចទទួលបានរង្វាន់នោះទេ ព្រោះពេលខ្លះមានសមាជិកក្រុមអវត្តមាន និងនៅពេលខ្លះម៉ាស៊ីនខូចៗ យ៉ាងណាមិញ ភាគីនិយោជកបានបញ្ជាក់ថា ការអនុវត្តថ្មីនេះ គឺផ្តល់អត្ថប្រយោជន៍ដល់កម្មករនិយោជិតប្រសើរជាងមុន ហើយនៅពេលដែលមានសមាជិកក្រុមអវត្តមាន, ខូចម៉ាស៊ីន, ខ្វះក្រណាត់ ឬខ្វះអំបោះ និយោជកតែងតែបន្ថយចំនួនគោលដៅតាមសមាមាត្រនៃចំនួនកម្មករនិយោជិតនៃក្រុមនីមួយៗ និងតាមភាពជាក់ស្តែងនៃបញ្ហា ពីព្រោះបញ្ហាទាំងនេះជាបន្ទុករបស់និយោជក។

យោងតាមតារាងប្រាក់រង្វាន់តាមក្តារខៀនដែលកម្មករនិយោជិតទទួលបានសម្រាប់ខែកុម្ភៈ, ខែមីនា, ខែមិថុនា និងខែកក្កដា ឆ្នាំ២០២១ ភាគីនិយោជកបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលពិនិត្យឃើញថា នៅពេលដែលនិយោជកអនុវត្តគោលការណ៍ប្រាក់រង្វាន់តាមក្តារខៀនថ្មី នៅខែមិថុនា និងខែកក្កដា ឆ្នាំ២០២១ កម្មករនិយោជិតនៅខ្សែចង្វាក់ផលិតកម្មចំនួន ៩ (ខ្សែចង្វាក់ផលិតកម្មលេខ ១, ២, ៥, ៧, ៩, ១០, ១១, ១៥, ១៦) ក្នុងចំណោមខ្សែចង្វាក់ផលិតកម្មសរុបចំនួន ១៤ខ្សែ ទទួលបានប្រាក់រង្វាន់តាមក្តារខៀនច្រើនជាងនៅខែកុម្ភៈ និងខែមីនា ឆ្នាំ២០២១ នៅពេលដែលនិយោជកអនុវត្តគោលការណ៍ប្រាក់រង្វាន់តាមក្តារខៀនចាស់។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានទទួលការលើកឡើង ឬការជំទាស់ពីភាគីកម្មករនិយោជិតលើតារាងប្រាក់រង្វាន់តាមក្តារខៀនដែលកម្មករនិយោជិតទទួលបានសម្រាប់ខែកុម្ភៈ, ខែមីនា, ខែមិថុនា និងខែកក្កដា ឆ្នាំ២០២១ ដែលភាគីនិយោជកបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា នៅពេលអនុវត្តគោលការណ៍ថ្មីនៃការផ្តល់ប្រាក់រង្វាន់តាមក្តារខៀន កម្មករនិយោជិតភាគច្រើនអាចធ្វើការបានដល់គោលដៅទទួលបានប្រាក់រង្វាន់ច្រើនជាងការអនុវត្តគោលការណ៍ចាស់ ដែលស្របនឹងការលើកឡើងរបស់ភាគីនិយោជក។

យោងតាមតារាងប្រាក់រង្វាន់តាមក្តារខៀនសម្រាប់ថ្ងៃទី១៥ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ ដែលភាគីនិយោជកបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលនៅថ្ងៃទី១៥ និយោជកបានកំណត់គោលដៅចំនួន ១៩៦០ ក្នុងការធ្វើការរយៈពេល ១០ម៉ោង និងមានចំនួនកម្មករនិយោជិតធ្វើការចំនួន ២៨នាក់។ នៅថ្ងៃទី១៦ និយោជកបានកំណត់គោលដៅចំនួន ១២៦០ សម្រាប់រយៈពេលធ្វើការ ៦ម៉ោង និងមានកម្មករនិយោជិតធ្វើការចំនួន ៣០នាក់ ហើយនៅថ្ងៃទី១៧ និយោជកបានកំណត់គោលដៅចំនួន ២១០០ សម្រាប់រយៈពេលធ្វើការ ១០ម៉ោង និងមានកម្មករនិយោជិតធ្វើការចំនួន ៣០នាក់។ តាមរយៈតារាងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា នៅពេលគ្មានផ្ទាំងក្រណាត់នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ និយោជកបានបន្ថយចំនួនគោលដៅតាមសមាមាត្រចំនួនកម្មករនិយោជិតនៃក្រុមនីមួយៗ និងតាមភាពជាក់ស្តែង ស្របតាមការអះអាងរបស់ភាគីនិយោជកក្នុងសវនាការ ដោយភាគីកម្មករនិយោជិតមិនបានជំទាស់ទៅនឹងតារាងប្រាក់រង្វាន់តាមក្តារខៀននេះទេ។

ផ្អែកតាមអង្គហេតុ និងភស្តុតាងខាងលើ នៅពេលអនុវត្តគោលការណ៍ថ្មីនៃប្រាក់រង្វាន់តាមក្តារខៀន កម្មករនិយោជិតភាគច្រើនទទួលបានប្រាក់រង្វាន់ច្រើនជាងមុន ហើយនៅពេលមានបញ្ហាដូចជាគ្មានផ្ទាំងក្រណាត់ និយោជកបានបន្ថយចំនួនគោលដៅតាមសមាមាត្រចំនួនកម្មករនិយោជិតនៃក្រុមនីមួយៗ និងតាមភាពជាក់ស្តែង។ ការអនុវត្តថ្មីនេះ មិនបានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងអត្ថប្រយោជន៍ស្របច្បាប់របស់កម្មករនិយោជិតនោះទេ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកបានប្រើប្រាស់សិទ្ធិគ្រប់គ្រងរបស់ខ្លួនក្នុងការផ្លាស់ប្តូរការអនុវត្តផ្តល់ជូនប្រាក់រង្វាន់តាមក្តារខៀន ស្របច្បាប់ និងសមហេតុផល។

THE ARBITRATION COUNCIL

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ និងរក្សាប្រាក់រង្វាន់តាមក្តារខៀន ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ ជូនកម្មករនិយោជិត។

**ខ. ប្រាក់ឈ្នួលតាមបរិមាណផលិតផល (ប្រាក់ដេរស៊ីបុង)**

នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានលើកឡើងថា ការផ្តល់ប្រាក់ឈ្នួលតាមបរិមាណផលិតផល គឺជាការអនុវត្តកន្លងមកតាំងពីឆ្នាំ២០១៤។

ជាដំបូង ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើការផ្តល់ប្រាក់ឈ្នួលតាមបរិមាណផលិតផល (ប្រាក់ឈ្នួលស៊ីបុង) គឺជាការអនុវត្តកន្លងមកដែរ ឬទេ?

នៅក្នុងសំណុំរឿងលេខ ៩៥/០៩-តាក ហ្វាត ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា៖ *"គោលការណ៍ "ការអនុវត្តកន្លងមក" ជាពាក្យ បច្ចេកទេសច្បាប់ និងជាគោលការណ៍របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលអនុញ្ញាតឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយវិវាទដោយពិនិត្យឡើងវិញ នូវការអនុវត្តដ៏ពិតប្រាកដមួយនៅក្នុងក្រុមហ៊ុន"*។

គោលការណ៍ច្បាប់នៃ ***"ការអនុវត្តកន្លងមក"*** ត្រូវបានគាំទ្រដោយបញ្ញត្តិច្បាប់ស្តីពីការងារមាត្រា ៦៥ កថាខណ្ឌទី ២ និងទី ៣។

កថាខណ្ឌទី២ នៃមាត្រា ៦៥ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា៖ *"កិច្ចសន្យានេះ អាចធ្វើជាលាយលក្ខណ៍អក្សរ ឬ ដោយមាត់ទទេ។ "កិច្ចសន្យានេះ អាចសរសេរ និងចុះហត្ថលេខាទៅតាមទំលាប់ស្រុក" ហើយប្រសិនជាត្រូវចុះបញ្ជិកាក៏ត្រូវធ្វើដោយឥតបង់ពន្ធអ្វីឡើយ។"*

កថាខណ្ឌទី៣ នៃមាត្រាដដែល ចែងថា៖ *"កិច្ចសន្យាធ្វើដោយមាត់ទទេ ត្រូវទុកដូចជាមានការព្រមព្រៀង រវាងនិយោជក និងកម្មករនិយោជិត តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងបទបញ្ជាការងារ ទោះបីមិនមានបញ្ជាក់ច្បាស់លាស់ក៏ដោយ។"*

ផ្អែកតាមខ្លឹមសារច្បាប់ដែលផ្តល់នៅក្នុងបរិបទនៃច្បាប់ស្តីពីការងារ ការអនុវត្តកន្លងមក គឺជាទម្លាប់ ឬការអនុវត្តដែលបានទទួលស្គាល់ដោយភាគីទាំងពីរ និងបានអនុវត្តជាច្រើនដងមកហើយនៅក្នុងអតីតកាល។ ពេលខ្លះ ការអនុវត្តបែបនេះ មិនចាំបាច់បង្កើតឡើងតាមរយៈការសរសេរជាលាយលក្ខណ៍អក្សរដោយភាគីអនុវត្តឡើយ។ ការអនុវត្តមួយ ត្រូវបានបង្កើតឡើង និងទទួលស្គាល់ថា ជាការអនុវត្តកន្លងមក នៅពេលដែលការអនុវត្តនោះ ធ្វើឡើងតាមរយៈសកម្មភាពទៀងទាត់ និងដដែលៗ។

នៅក្នុងសំណុំរឿងលេខ ៩៥/០៩-តាក ហ្វាត ហេតុផលចំណុចវិវាទទី២ ក្រុមប្រឹក្សាអាជ្ញាកណ្តាលឱ្យនិយមន័យ ***"ការអនុវត្តកន្លងមក"*** ថា ជាការអនុវត្តមួយ ដែលបានប្រព្រឹត្តរួចជាយូរមកហើយ និងដែលបានកើតឡើង ជាដដែលៗ ដែលមានភាពច្បាស់លាស់ ស្ថិតស្ថេរ និងមានការទទួលស្គាល់ និងទទួលយកដោយភាគីកម្មករនិយោជិត និងនិយោជក។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចលើការអនុវត្តកន្លងមកជាច្រើនចំពោះករណីមួយចំនួន ដូចជា (១)-ការប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំ *(សេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២១/០៥-ស៊ីណូមេក ហេតុផលចំណុចវិវាទទី១)*, (២)-ការទូទាត់ប្រាក់ឈ្នួល *(១៤/០៦-សេង យ៉ុង ហេតុផលចំណុចវិវាទទី១)*, (៣)-ការបង់ជូននូវប្រាក់រង្វាន់ *(១៨/០៧-ទ្រីណុងហ្គាល កុមារា ហេតុផលចំណុចវិវាទទី ២)* និង(៤)-ការផ្តល់ជូនប្រាក់ថ្លៃបាយ *(១៣៦/០៧-ភ្នំពេញ ហ្គាមិន ហេតុផលចំណុចវិវាទទី១)* ជាដើម។

ប៉ុន្តែ ទន្ទឹមនឹងនេះដែរ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការអនុវត្តខ្លះមិនមែនជា ***"ការអនុវត្តកន្លងមក"*** ទេ តួយ៉ាងដូចជា ការអនុវត្តដែលទាក់ទងទៅនឹងចង្វាក់ផលិតកម្មការងាររបស់ក្រុមហ៊ុនដែលត្រូវស្ថិត

THE ARBITRATION COUNCIL

នៅក្រោមការដឹកនាំ និងគ្រប់គ្រងរបស់និយោជក។ *(សូមមើលសេចក្តីបង្គាប់របស់អាជ្ញាកណ្តាលលេខ ១១៦/០៧-ហ្គ្រេស សាន់ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី២ និងលេខ ១១៤/០៧-យ៉ូនៀន ផេគើរ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១)*

នៅក្នុងសំណុំរឿងលេខ ៤៤/០៦-ហ្គោល ហេម ហេតុផលនៃចំណុចវិវាទទី៣ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ៖ "*សិទ្ធិក្នុងការគ្រប់គ្រងសហគ្រាសរបស់និយោជកនេះ រួមបញ្ចូលទាំងសិទ្ធិក្នុងការកំណត់ថា តើកម្មករនិយោជិតផ្នែកណាខ្លះត្រូវធ្វើការតាមតម្លៃឡូត៍ ហើយកម្មករនិយោជិតផ្នែកណាខ្លះទៀតត្រូវធ្វើការតាមប្រាក់ឈ្នួលកំណត់*"។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការសម្រេចអនុវត្ត ឱ្យកម្មករនិយោជិតធ្វើការយកប្រាក់ឈ្នួលតាមបរិមាណផលិតផល ឬធ្វើការយកប្រាក់ឈ្នួលប្រចាំខែ គឺស្ថិតនៅក្រោមសិទ្ធិដឹកនាំ និងគ្រប់គ្រងរបស់និយោជក ពីព្រោះការអនុវត្តនេះ គឺទាក់ទងទៅនឹងចង្វាក់ផលិតកម្មការងាររបស់ក្រុមហ៊ុន ពោលគឺការចាត់ចែងរបស់និយោជក ក្នុងការកំណត់ឱ្យកម្មករនិយោជិតធ្វើការទទួលបានប្រាក់ឈ្នួលប្រចាំខែ នាំឱ្យកម្មករនិយោជិតអាចធ្វើការមានសន្ទុះស្មើគ្នា និងដោះស្រាយបញ្ហានៃការស្ទះចង្វាក់ផលិតកម្ម។

*(សូមមើលការបកស្រាយមាត្រា ២ នៃច្បាប់ស្តីពីការងារ អំពីសិទ្ធិចាត់ចែងរបស់និយោជក នៅក្នុងចំណុចវិវាទទី ១-ក ខាងលើ។)*

នៅក្នុងសវនាការ ភាគីនិយោជកបានបញ្ជាក់ថា នៅពេលនិយោជកអនុវត្តប្រាក់ឈ្នួលតាមបរិមាណផលិតផល គឺមានកម្មករនិយោជិតតែចំនួនជាង ២០០នាក់ប៉ុណ្ណោះ ក្នុងចំណោមកម្មករនិយោជិតចំនួន ៧០០ នាក់ ដែលទទួលបានប្រាក់ឈ្នួលតាមបរិមាណផលិតផល ដោយមិនចាំបាច់បន្ថែមឱ្យគ្រប់ប្រាក់ឈ្នួលអប្បបរមា។ ហេតុនេះ និយោជកបានផ្លាស់ប្តូរការអនុវត្តថ្មី ដោយផ្តល់ប្រាក់ឈ្នួលប្រចាំខែ ជូនកម្មករនិយោជិតវិញ។ នៅពេលអនុវត្តផ្តល់ប្រាក់ឈ្នួលប្រចាំខែ និយោជកបានបន្ថែមប្រាក់ចំនួន ២ដុល្លារ ទៅ ៥ដុល្លារ ទៀត ពីលើប្រាក់ឈ្នួលគោល(ចំនួន ១៩២ដុល្លាអាមេរិក) របស់កម្មករនិយោជិត ដោយអាស្រ័យលើជំនាញ និងបទពិសោធន៍របស់កម្មករនិយោជិត ហើយការអនុវត្តថ្មីនេះ ធ្វើឱ្យកម្មករនិយោជិតធ្វើការក្នុងល្បឿនស្មើគ្នា និងមិនស្ទះដល់ចង្វាក់ផលិតកម្ម។

ភាគីកម្មករនិយោជិតបានលើកឡើងថា ការផ្លាស់ប្តូរនេះ ធ្វើឱ្យបាត់បង់អត្ថប្រយោជន៍របស់កម្មករនិយោជិត ពីព្រោះពីមុនមក កម្មករនិយោជិតតែងតែធ្វើការទទួលបានប្រាក់ឈ្នួលប្រមាណ ២០០ ទៅ ៣០០ ដុល្លារអាមេរិក ក្នុងមួយខែ។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីដែលធ្វើការអះអាង ឬចោទប្រកាន់ គឺមានបន្ទុកភស្តុតាង។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៧៩/០៥-អេរ៉ូហ្គ្រីន, លេខ ១០១/០៨-ជីឌីអ៊ីម ហេតុផលនៃចំណុចវិវាទទី១ និងទី២, លេខ ១៦៨/០៨-ទឹកថ្លា ផ្កាហ្វា ហេតុផលនៃចំណុចវិវាទទី២, លេខ ១១៥/១០-ជី-ហ្វម៉ូស ហេតុផលនៃចំណុចវិវាទទី១៨, លេខ ១៤៨/១១-ដាយ យ៉ាំង, និងលេខ ២៧៦/១៥-មិត្តភាព ហ្គាមិន ហេតុផលនៃចំណុចវិវាទទី១)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ បានបដិសេធការទាមទារ ឬច្រានចោលការអះអាងរបស់ភាគីវិវាទ ប្រសិនបើភាគីដែលធ្វើការទាមទារ ឬធ្វើការអះអាងនោះ មិនមានមូលដ្ឋានគ្រប់គ្រាន់ ឬភស្តុតាងជាក់លាក់ ដើម្បីគាំទ្រនូវការទាមទារ ឬការអះអាងរបស់ខ្លួន។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ*

THE ARBITRATION COUNCIL

*៦៣/០៤-សាញ វែល ហេតុផលនៃចំណុចវិវាទទី៤, លេខ ៩៩/០៦-សៅធ៍បាយ ហេតុផលនៃចំណុចវិវាទទី៥, លេខ ៣៣/០៧-ហ្គោលហ្វេម ហេតុផលនៃចំណុចវិវាទទី៤, លេខ ៥១/០៧-ហ្គោលហ្វេម ហេតុផលនៃចំណុចវិវាទទី៣, និងលេខ ០៣២/១៦-អ៊ីជើនិធី ក្លូបិល ស្ព័តជីង (ខេមបូឌា) ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី១)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញា-កណ្តាលនៅក្នុងសំណុំរឿងមុនៗខាងលើដែរ។

ក្រៅពីការអះអាងនៅក្នុងសវនាការ និងសារណារបស់ភាគីកម្មករនិយោជិត ភាគីកម្មករនិយោជិតមិនបានដាក់ឯកសារ ឬភស្តុតាងណាមួយ ដើម្បីបញ្ជាក់ថា កម្មករនិយោជិតតែងតែធ្វើការទទួលបានប្រាក់ឈ្នួលប្រមាណ ២០០ ទៅ ៣០០ដុល្លារអាមេរិក ក្នុងមួយខែ មុនផ្លាស់ប្តូរមកការអនុវត្តគោលការណ៍ថ្មីនេះទេ ហើយភាគីកម្មករនិយោជិតមិនមានបញ្ជាក់ពីចំនួនកម្មករនិយោជិតដែលធ្លាប់ទទួលប្រាក់ឈ្នួល ប្រមាណ ២០០ ទៅ ៣០០ដុល្លារអាមេរិក ក្នុងមួយខែ និងចំនួនកម្មករនិយោជិតដែលមិនទទួលបានប្រាក់ឈ្នួលដូចនៅពេលការអនុវត្តគោលការណ៍ចាស់ ដែលធ្វើឱ្យប៉ះពាល់ដល់អត្ថប្រយោជន៍របស់កម្មករនិយោជិតនោះទេ។

នៅពេលអនុវត្តផ្តល់ប្រាក់ឈ្នួលប្រចាំខែជូនកម្មករនិយោជិត និយោជកបានបន្ថែមប្រាក់ចំនួន ២ដុល្លារ ទៅ ៥ដុល្លារ ទៀត ពីលើប្រាក់ឈ្នួលគោលរបស់កម្មករនិយោជិត ដោយអាស្រ័យលើជំនាញ និងបទពិសោធន៍របស់គាត់ដែលមានចំនួនលើសពីប្រាក់ឈ្នួលអប្បបរមាដែលកំណត់ដោយច្បាប់។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញា-កណ្តាលយល់ឃើញថា ការចាត់ចែងរបស់និយោជកមិនបានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងអត្ថប្រយោជន៍ស្របច្បាប់ណាមួយរបស់កម្មករនិយោជិតនោះ ពោលគឺនិយោជកចាត់ចែងឱ្យកម្មករនិយោជិតធ្វើការទទួលបានប្រាក់ឈ្នួលប្រចាំខែ ដោយស្របច្បាប់ និងសមហេតុផល។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលតាមបរិមាណផលិតផល ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ ជូនកម្មករនិយោជិត។

**គ. ប្រាក់រង្វាន់ដេរប្តូរស្នាយ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចផ្តល់ប្រាក់រង្វាន់ដេរប្តូរស្នាយជូនកម្មករនិយោជិតដែរ ឬទេ?

យោងកថាខណ្ឌទី ៣ ប្រការ ៨ នៃអនុសញ្ញារួមរវាងក្រុមហ៊ុន ខេមបូស៊ីន ហ្វេងជីង ហ្គាមេន ខូ អិលធីឌី (គួ តាយ ហ័រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន) ជាមួយនឹងសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ខេមបូស៊ីន ហ្វេងជីង ហ្គាមេន ខូ អិលធីឌី (គួរ តាយ ហ័រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន) ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ ចែងថា ៖ "*ក្រុមហ៊ុនឯកភាពក្នុងការផ្តល់ប្រាក់រង្វាន់ដូរស្នាយ ក្នុងមួយស្នាយ ៦ដុល្លារ នៅពេលដែលមានការដូរស្នាយ*"។

នៅក្នុងសវនាការ ភាគីទាំងពីរទទួលស្គាល់ថា នៅពេលដែលនិយោជកតម្រូវឱ្យកម្មករនិយោជិតប្តូរស្នាយដេរ និយោជកផ្តល់ប្រាក់រង្វាន់ដេរប្តូរស្នាយជូនកម្មករនិយោជិត ចំនួន ៦ដុល្លារអាមេរិក។ ចាប់ពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១ និយោជកចាប់ផ្តើមបញ្ឈប់អនុវត្តផ្តល់ជូនប្រាក់រង្វាន់ដេរប្តូរស្នាយនេះ។ ភាគីនិយោជកបានលើកឡើងថា កថាខណ្ឌទី៣ ប្រការ ៨ នៃអនុសញ្ញារួម គឺអនុវត្តចំពោះតែកម្មករនិយោជិតធ្វើការបានប្រាក់ឈ្នួលតាមបរិមាណផលិតផលតែប៉ុណ្ណោះ ប៉ុន្តែបច្ចុប្បន្ន និយោជកលែងអនុវត្តឱ្យកម្មករនិយោជិតធ្វើការទទួលបានប្រាក់ឈ្នួលតាមបរិមាណផលិតផលទៀតហើយ ហេតុនេះ កម្មករនិយោជិតមិនអាចទទួលបានប្រាក់រង្វាន់ដេរប្តូរស្នាយទៀតទេ។

THE ARBITRATION COUNCIL

យោងតាមកថាខណ្ឌទី៣ ប្រការ ៨ នៃអនុសញ្ញារួមខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា ភាគីនិយោជកបានឯកភាពក្នុងការផ្ដល់ប្រាក់រង្វាន់ដេរប្ដូរស្ពាយ ក្នុងមួយស្ពាយចំនួន ៦ដុល្លារអាមេរិក នៅពេលដែលមានការប្ដូរស្ពាយ ហើយមិនបានកំណត់ថា ការផ្ដល់ជូនប្រាក់រង្វាន់ដេរប្ដូរស្ពាយចំនួន ៦ដុល្លារអាមេរិកនេះ មានភ្ជាប់ជាមួយលក្ខខណ្ឌ ក្នុងការផ្ដល់ជូនសម្រាប់តែកម្មករនិយោជិតដែលធ្វើការទទួលបានប្រាក់ឈ្នួលតាមបរិមាណផលិតផលនោះទេ។

ហេតុនេះ យោងតាមកថាខណ្ឌទី៣ ប្រការ ៨ នៃអនុសញ្ញារួមខាងលើ និយោជកមានកាតព្វកិច្ចត្រូវអនុវត្តទៅតាមខ្លឹមសារនៃអនុសញ្ញារួមដែលបានព្រមព្រៀងជាមួយនឹងសហជីពប្រជាធិបតេយ្យកម្មករ នៃក្រុមហ៊ុន ខេមបូស៊ីន ហ្វេងជីង ហ្គាមេន ខូ អិលធីឌី ក្នុងការផ្ដល់ជូនប្រាក់រង្វាន់ដេរប្ដូរស្ពាយចំនួន ៦ដុល្លារអាមេរិកជូនកម្មករនិយោជិត។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេច បង្គាប់ឱ្យនិយោជកផ្ដល់ និងរក្សាប្រាក់រង្វាន់ដេរប្ដូរស្ពាយចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ ជូនកម្មករនិយោជិត។

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារឱ្យនិយោជកផ្ដល់ប្រាក់ឈ្នួលចំនួន ៥០ភាគរយ ជូនកម្មករនិយោជិត សម្រាប់ថ្ងៃទី១៥ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ ក្នុងអំឡុងពេលវិធានការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្ដាល**

ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចផ្ដល់ប្រាក់ឈ្នួលចំនួន ៥០ភាគរយ ជូនកម្មករនិយោជិត សម្រាប់ថ្ងៃទី១៥ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ ក្នុងអំឡុងពេលវិធានការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្ដាលដែរ ឬទេ?

ចំណុចទី២ និងទី៣ នៃសេចក្ដីណែនាំ លេខ ០៤៣/២១ ក.ប/ស.ណ.ន.ខ.ល របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ស្ដីពីការបើកផ្ដល់ប្រាក់ឈ្នួលដើមខែមេសា និងប្រាក់ឧបត្ថម្ភបន្ថែមរបស់រោងចក្រ សហគ្រាស សិប្បកម្ម និងក្រុមហ៊ុន ដល់កម្មករនិយោជិតក្នុងអំឡុងពេលនៃការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្ដាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ចែងថា ៖ "*យោងតាមច្បាប់ស្ដីពីការងារ ការផ្អាកសកម្មភាពអាជីវកម្មរបស់រោងចក្រ សហគ្រាស សិប្បកម្ម និងក្រុមហ៊ុនដោយសារការអនុវត្តវិធានការបិទខ្ទប់ជាបណ្ដោះអាសន្ននៅភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅ នាំឱ្យមានការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត។ ដើម្បីជានាផលប្រយោជន៍របស់បងប្អូនកម្មករនិយោជិត នៅក្នុងអំឡុងពេលបិទខ្ទប់នេះ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ សូមធ្វើការណែនាំដល់ម្ចាស់ ឬនាយករោងចក្រ សហគ្រាស សិប្បកម្ម និងក្រុមហ៊ុន ដែលត្រូវផ្អាកសកម្មភាពអាជីវកម្មក្នុងអំឡុងពេលបិទខ្ទប់ ដូចខាងក្រោម ៖*

*...*

*២. ត្រូវបើកផ្ដល់ប្រាក់ឈ្នួលដើមខែមេសា (ប្រាក់ឈ្នួលសម្រាប់ថ្ងៃទី០១ ដល់ថ្ងៃទី១៤ ខែមេសា ឆ្នាំ ២០២១) ជូនកម្មករនិយោជិតរបស់ខ្លួន ប្រសិនជាមិនទាន់បានបើកផ្ដល់នាពេលកន្លងមក។ ការបើកផ្ដល់នេះសូមធ្វើនៅក្រោយពេលចប់វិធានការបិទខ្ទប់។*

*៣. ផ្ដល់ប្រាក់ឧបត្ថម្ភបន្ថែមជូនដល់កម្មករនិយោជិតរបស់ខ្លួនទៅតាមលទ្ធភាព ដោយផ្អែកលើស្មារតីមនុស្សធម៌ សាមគ្គីភាព និងទំនួលខុសត្រូវសង្គមនៅក្នុងគ្រាលំបាកនេះ។ ការបើកផ្ដល់ប្រាក់ឧបត្ថម្ភបន្ថែមនេះក៏សូមធ្វើនៅក្រោយពេលចប់វិធានការបិទខ្ទប់*"។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា សេចក្ដីណែនាំ ០៤៣/២១ បានកំណត់អំពីកាតព្វកិច្ចរបស់និយោជកក្នុងការផ្ដល់ប្រាក់ឈ្នួលសម្រាប់ថ្ងៃទី០១ ដល់ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ បន្ថែមពីនេះ ក៏បានកំណត់

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល THE ARBITRATION COUNCIL

កាតព្វកិច្ចឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតសម្រាប់ថ្ងៃទី១៥ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ ទេ ដោយគ្រាន់តែណែនាំឱ្យនិយោជកផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមជូនដល់កម្មករនិយោជិតតាមលទ្ធភាព ដោយផ្អែកលើស្មារតីមនុស្សធម៌ សាមគ្គីភាព និងទំនួលខុសត្រូវសង្គមក្នុងគ្រាលំបាក ពីព្រោះសេចក្តីណែនាំនេះបានបញ្ជាក់ថា ការផ្អាកសកម្មភាពអាជីវកម្មរបស់រោងចក្រ សហគ្រាស សិប្បកម្ម និងក្រុមហ៊ុន ដោយសារការអនុវត្តវិធានការបិទខ្ទប់ជាបណ្តោះអាសន្ននៅភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅ នាំឱ្យមានការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត។

ករណីនេះ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលចំនួន ៥០ភាគរយ ជូនកម្មករនិយោជិត សម្រាប់ថ្ងៃទី១៥ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ ក្នុងអំឡុងពេលវិធានការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល។ ដោយហេតុថា សេចក្តីណែនាំខាងលើមិនបានកំណត់កាតព្វកិច្ចឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតសម្រាប់ថ្ងៃទី១៥ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ ក្នុងអំឡុងពេលអនុវត្តវិធានការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមិនមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលចំនួន ៥០ភាគរយ ជូនកម្មករនិយោជិត សម្រាប់ថ្ងៃទី១៥ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ ក្នុងអំឡុងពេលវិធានការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាលនោះទេ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលចំនួន ៥០ភាគរយ ជូនកម្មករនិយោជិត សម្រាប់ថ្ងៃទី១៥ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ ក្នុងអំឡុងពេលវិធានការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល។

**ចំណុចវិវាទទី ៣ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលចំនួន ១០០ភាគរយ សម្រាប់ខែឧសភា ឆ្នាំ២០២១ ជូនកម្មករនិយោជិត នៅក្នុងអំឡុងពេលនៃវិធានការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល**

ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលចំនួន ១០០ភាគរយ សម្រាប់ខែឧសភា ឆ្នាំ២០២១ ជូនកម្មករនិយោជិត នៅពេលដែលកម្មករនិយោជិតមិនអាចមកធ្វើការបានដោយសារវិធានការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាលដែរ ឬទេ ?

មាត្រា ១០២ នៃច្បាប់ស្តីពីការងារ ចែងថា ៖ *"តាមន័យនៃច្បាប់នេះ ពាក្យថាប្រាក់ឈ្នួល ទោះបីការកំណត់ ឬរបៀបគិតយ៉ាងណាក៏ដោយមានន័យថា ឈ្នួលការងារ ឬឈ្នួលសេវា ដែលអាចគិតជាប្រាក់បាន ឬកំរិតបានដោយការព្រមព្រៀងគ្នា ឬដោយច្បាប់ជាតិ ហើយដែលនិយោជកត្រូវបើកឱ្យកម្មករនិយោជិតតាមកិច្ចសន្យាជួលការងារ ឬសេវាដោយលាយលក្ខណ៍អក្សរ ឬដោយមាត់ទទេ ទោះចំពោះការងារដែលបានធ្វើក្តី ឬដែលត្រូវធ្វើក្តី ចំពោះសេវាដែលបានបំពេញ ឬត្រូវបំពេញក្តី"*។

នៅក្នុងសំណុំរឿងលេខ ២០៨/១២-អូសេអង់ ហ្គាមិន ហេតុផលនៃចំណុចវិវាទទី១ ក្រុមប្រឹក្សាអាជ្ញា-កណ្តាលបកស្រាយថា ៖ *"យោងតាមមាត្រា ១០២ នៃច្បាប់ស្តីពីការងារខាងលើនេះមានន័យថា និយោជកត្រូវបើកប្រាក់ឈ្នួលដល់កម្មករនិយោជិតតាមកិច្ចសន្យាដែលបានចែង។ នេះមានន័យថា ក្នុងរយៈពេល ដែលកម្មករនិយោជិតធ្វើការងារឱ្យនិយោជក និយោជកត្រូវបើកប្រាក់ឈ្នួល ដែលបានធ្វើឱ្យកម្មករនិយោជិត"*។

នៅក្នុងសវនាការ ភាគីទាំងពីរទទួលស្គាល់ថា ក្រុមហ៊ុន គួ តាយ ហ៊ា សេង ស៊ីន ហ្វេស៊ីង (ខេមបូឌា) ហ្គាម៉ិន គឺស្ថិតនៅសង្កាត់ស្ទឹងមានជ័យ ហើយត្រូវបានរាជរដ្ឋាភិបាលកំណត់ជាតំបន់ក្រហមតាំងពីថ្ងៃទី១២



THE ARBITRATION COUNCIL

ខែឧសភា ឆ្នាំ២០២១។ នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ ក្រុមហ៊ុននេះ បានចាប់ផ្តើមបើកដំណើរការឡើងវិញ ប៉ុន្តែកម្មករនិយោជិតមួយចំនួនដែលមានទីលំនៅ ឬទីសំណាក់ស្ថិតនៅក្នុងភូមិសាស្ត្រដែលត្រូវបានកំណត់ជាតំបន់ក្រហម មិនអាចមកធ្វើការបាន រហូតដល់ថ្ងៃទី២៦ ឬទី២៧ ខែឧសភា ឆ្នាំ២០២១។ ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៧០០នាក់ មានកម្មករនិយោជិតតែចំនួនជាង ២០០ ទៅ ៣០០នាក់ប៉ុណ្ណោះ ដែលបានមកធ្វើការ ចាប់ពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១។

ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលកត់សម្គាល់ឃើញថា កម្មករនិយោជិត ឬនិយោជកមិនអាចបំពានវិធានការរដ្ឋបាល ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នោះទេ ហេតុនេះ នៅពេលដែលកម្មករនិយោជិតមានទីលំនៅ ឬទីសំណាក់ស្ថិតនៅក្នុងភូមិសាស្ត្រដែលត្រូវបានកំណត់មិនឱ្យចេញ ឬចូល កម្មករនិយោជិតមិនអាចទៅបំពេញការងាររបស់ខ្លួនបានទេ ហើយការដែលកម្មករនិយោជិតមិនអាចទៅធ្វើការបាន គឺមិនមែនជាកំហុស ឬបន្ទុករបស់កម្មករនិយោជិត ឬនិយោជកនោះទេ។ ទោះជាយ៉ាងណានេះក៏ដោយ យោងតាមមាត្រា ១០២ និងការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ករណីនេះ ក្នុងអំឡុងពេលដែលកម្មករនិយោជិតមិនបានធ្វើការងារឱ្យនិយោជក និយោជកមិនមានកាតព្វកិច្ចក្នុងការផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតនោះទេ ពីព្រោះមាត្រា ១០២ នៃច្បាប់ស្តីពីការងារ បានកំណត់យ៉ាងច្បាស់អំពីកាតព្វកិច្ចរបស់និយោជកក្នុងការផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិត ក្នុងរយៈពេលដែលកម្មករនិយោជិតធ្វើការងារឱ្យនិយោជកប៉ុណ្ណោះ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលចំនួន ១០០ភាគរយ សម្រាប់ខែឧសភា ឆ្នាំ២០២១ ជូនកម្មករនិយោជិត នៅក្នុងអំឡុងពេលនៃវិធានការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និងបង្គាប់

**ចំណុចវិវាទទី ១ ៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ និងរក្សាប្រាក់រង្វាន់តាមក្តារខៀន ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ ជូនកម្មករនិយោជិត។
- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ និងរក្សាប្រាក់ដេរស៊ីបុង (ប្រាក់ឈ្នួលតាមបរិមាណផលិតផល) ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ ជូនកម្មករនិយោជិត។
- បង្គាប់ឱ្យនិយោជកផ្តល់ និងរក្សាប្រាក់រង្វាន់ដេរប្តូរស្តាយ ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ ជូនកម្មករនិយោជិត។

**ចំណុចវិវាទទី ២ ៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលចំនួន ៥០ភាគរយ ជូនកម្មករនិយោជិត សម្រាប់ថ្ងៃទី១៥ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ ក្នុងអំឡុងវិធានការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល។

THE ARBITRATION COUNCIL

ចំណុចវិវាទទី ៣ ៖

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលចំនួន ១០០ភាគរយ សម្រាប់ខែឧសភា ឆ្នាំ២០២១ ជូនកម្មករនិយោជិត នៅក្នុងអំឡុងពេលនៃវិធានការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល។

ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់ជាប់កាតព្វកិច្ច

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង យោងតាមអនុសញ្ញារួម រវាងក្រុមហ៊ុន ខេមបូស៊ីន ហ្វេង ជីង ហ្គាមេន ខូអិលធីឌី (គួ តាយ ហ័រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា)ហ្គាម៉ិន) ជាមួយនិងសហជីពប្រជាធិបតេយ្យកម្មករ នៃក្រុមហ៊ុន ខេមបូស៊ីន ហ្វេង ជីង ហ្គាមេន ខូអិលធីឌី (គួ តាយ ហ័រ សេង ស៊ីន ហ្វេង ជីង(ខេមបូឌា)ហ្គាម៉ិន) ចុះបញ្ជីលេខ ០០២កប/អក/វក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា ៖ -----------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ស៊ីន គឹមស៊ាន**

ហត្ថលេខា ៖ -----------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉េន ម៉ុនណា**

ហត្ថលេខា ៖ -----------------------------

THE ARBITRATION COUNCIL